# “បច្ចេកទេសដាំដុះដំណាំស្រូវ”

## សៀវភៅណែនាំបច្ចេកទេសប្រតិបត្តការសាលារៀនស្រែកសិករ
## សម្រាប់មន្ត្រីផ្សព្វផ្សាយ

ដោយផ្អែកលើបទពិសោធន៍ដែលទទួលបានពី
“គម្រោងបង្កើនផលិតភាពកសិកម្មក្នុងតំបន់ទន្លេសាបប៉ែកខាងលិច”

ខែធ្នូ ឆ្នាំ២០១៤

ខេត្តបាត់ដំបង ប្រទេសកម្ពុជា

# អារម្ភកថា

ចាប់តាំងពីគម្រោងAPPP(គម្រោងបង្កើនផលិតភាពកសិកម្មក្នុងតំបន់ទន្លេសាបប៉ែកខាងលិច) អនុវត្តការងាររបស់ខ្លួនក្រោមការសហការណ៍គ្នារវាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទនៃព្រះរាជាណាចក្រកម្ពុជា និងទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន(JICA)បានចាប់ផ្តើមក្នុងខែតុលា ឆ្នាំ២០១០មក ទម្រង់ការងារសំខាន់ៗរបស់FFS(សាលារៀនស្រែកសិករ) ក្នុងការផ្ទេរបច្ចេកទេស និងសកម្មភាពផ្សព្វផ្សាយគឺត្រូវបានសាកល្បងអនុវត្តន៍។ ជាពិសេសការប្រឈមនូវកង្វះខាតប្រពន្ធ័គាំទ្របច្ចេកទេសផលិត និងប្រពន្ធ័ស្ថាបន័គាំទ្រដល់ការចែកចាយផលិតផលកសិកម្មរបស់ប្រជាជន ដូច្នេះមូលដ្ឋានរបស់សាលារៀនស្រែកសិករគឺប្រមូលផ្តុំកសិករបង្កើតជាក្រុមកសិករក្រោមសកម្មភាពរបស់គម្រោងAPPP ដែលមានដូចជា ក្រុមSGG (ក្រុមផលិតពូជស្រូវ) ដែលមានជំនាញខាងផលិតកម្មពូជស្រូវ និងក្រុមPG (ក្រុមសាកល្បង) គឺជាក្រុមកសិករដែលបានសិក្សា និងអនុវត្តគុណប្រយោជន៍នៃការធ្វើកសិកម្មជាក្រុម និងរួមបញ្ចូលទាំងការពង្រឹងការចែកចាយស្រូវផងដែរ។ សម្រាប់បញ្ហាការផ្សព្វផ្សាយពត៌មានបច្ចេកទេស កសិករត្រូវបានរៀបចំជាក្រុមDF (កសិករបង្ហាញ) ដែលមានតួនាទីជាក្រុមសម្រាប់ធ្វើបង្ហាញនូវការធ្វើឲ្យល្អប្រសើរឡើងនូវបច្ចេកទេសដាំដុះដំណាំស្រូវក្នុងគម្រោងចាប់តាំងពីដើមរដូវវស្សានាឆ្នាំ២០១១។ ជាការពិតណាស់ត្រឹមតែរយៈពេលមិនដល់បួនឆ្នាំផងនៃរយៈពេលសាកល្បង គម្រោងបានសិក្សាពីភាពលំបាកនិងលទ្ធភាពផ្សេងៗក្នុងពេលជាមួយគ្នាផងដែរ។ បញ្ហាចម្បងនោះគឺលក្ខខណ្ឌ័អាកាសធាតុដែលប្រែប្រួលយ៉ាងខ្លាំងពីមួយឆ្នាំទៅមួយឆ្នាំរវាងគ្រោះទឹកជំនន់ និងគ្រោះរាំងស្ងួត។ ម្យ៉ាងវិញទៀតកសិករមួយចំនួន និងក្រុមរបស់ពួកគេបានខិតខំធ្វើការយ៉ាងសកម្មដើម្បីដោះស្រាយបញ្ហាដែលបណ្តាលមកពីបំរែបំរួលអាកាសធាតុ។ បន្ថែមលើនេះទៅទៀតកសិករមួយចំនួនបានខិតខំយ៉ាងសកម្មក្នុងការជួយដល់កសិករជិតខាងក្នុងតំបន់របស់ពួកគេក្នុងការធ្វើឲ្យល្អប្រសើរឡើងនូវបច្ចេកទេសដាំដុះដំណាំស្រូវ។ កត្តាទាំងអស់នេះហើយបានធ្វើឲ្យគម្រោងAPPPជឿលើគោលគំនិតនៃប្រពន្ធ័ផ្សព្វផ្សាយពីកសិករ ទៅ កសិករ (Farmer To Farmer) អាចជាមធ្យោបាយមួយដ៏មានសារៈប្រយោជន៍ក្នុងការសម្រេចឲ្យបានជោគជ័យក្នុងការអភិវឌ្ឍន៍កសិកម្មដំណាំស្រូវនៅកម្ពុជា។

គម្រោងAPPP បានកំណត់នូវបច្ចេកទេសមួយចំនួនដែលអាចត្រូវបានអនុវត្តដោយអ្នកផលិតស្រូវនៅកម្ពុជា ហើយបច្ចេកទេសដែលបានណែនាំទាំងអស់នោះវាមានលក្ខណៈជាធម្មជាតិហើយសាមញ្ញបំផុត ហើយរាល់បច្ចេកទេសទាំងអស់នោះត្រូវបានដាក់បញ្ចូលក្នុងមាតិកានៃវគ្គបណ្តុះបណ្តាលសាលារៀនស្រែកសិករដែលមាននៅក្នុងសៀវភៅនេះ។ ផ្អែកលើបទពិសោធន៍ជិត៤ឆ្នាំធ្វើការជាមួយកសិករប្រមាណជាង៥,០០០នាក់ ក្នុងខេត្តបាត់ដំបង ពោធិ៍សាត់ និងកំពង់ឆ្នាំង គម្រោងAPPP បានទទួលលទ្ធផលមួយចំនួនដែលអាចបញ្ជាក់ពីប្រយោជន៍ដែលអាចទទួលបានតាមរយៈការអនុវត្តន៍បច្ចេកទេសរបស់កសិករទៅលើការដាំដុះដំណាំស្រូវរបស់ពួកគាត់។

សៀវភៅណែនាំបច្ចេកទេសប្រតិបត្តិការសាលារៀនស្រែកសិករនេះត្រូវបានផលិតឡើងពីលទ្ធផលនៃបទពិសោធន៍ និងការសម្រេចបានដូចដែលបានរៀបរាប់ខាងលើហើយវាមានគោលបំណងសម្រាប់ប្រើដោយក្រុមមនុស្សដែលពាក់ពន្ធ័ក្នុងការផ្សព្វផ្សាយបច្ចេកទេសសម្រាប់ផលិតកម្មដំណាំស្រូវ។ គោលគំនិត និងរបៀបរៀបចំវគ្គបណ្តុះបណ្តាលសាលារៀនស្រែកសិករដល់អ្នកដាំដុះដំណាំស្រូវគឺត្រូវបានពណ៌នានៅក្នុងសៀវភៅនេះ។ គម្រោង APPPសង្ឃឹមថាតាមការចែករំលែកបទពិសោធន៍តាមរយៈការប្រើប្រាស់សៀវភៅនេះ ចំនួនកសិករកាន់តែច្រើនឡើងគ្រប់ទីកន្លែងទូទាំងប្រទេសអាចទទួលបានឱកាសចូលរួមក្នុងវគ្គបណ្តុះបណ្តាលដើម្បីទទួលបានចំណេះដឹងជាក់ស្តែងក្នុងការកែលម្អការអនុវត្តន៍ធ្វើការងារកសិកម្មរបស់ពួកគាត់ដែលនាំឱ្យជីវភាពពួកគាត់ធូរធារ ហើយរួមចំណែកដល់ការអភិវឌ្ឍន៍ប្រទេសជាតិទាំងមូល។

គម្រោងAPPP ខែ ធ្នូ ឆ្នាំ២០១៤

និពន្ធដោយលោក កុជី ស៊ីម៉ូកាវា, ជំនាញការទទួលបន្ទុកផ្នែកផ្សព្វផ្សាយ និង បណ្តុះបណ្តាល(JICA)

## សន្ទស្សន៍


- លក្ខណៈសាលារៀនស្រែកសិករអនុវត្តដោយគម្រោងAPPP → ទំព័រ 4~6
- ទិដ្ឋភាពទូទៅនៃវគ្គបណ្តុះបណ្តាល និងការទទួលយកបច្ចេកទេស → ទំព័រ 7~9






- វិធីសាស្ត្រអ្នកសពគ្រោះដោយប្រើឧបករណ៍ → ទំព័រ 27~30
- តួនាទីរំពឹងទុកនៃមន្ត្រីផ្សព្វផ្សាយ កសិករបង្ហាញ និងកសិករចូលរួម → ទំព័រ 45
- ការកំណត់កាលបរិច្ឆេទរបស់សាលារៀនស្រែកសិករ (FFS) → ទំព័រ 46
- តារាងគម្រោងAPPPសម្រាប់វគ្គបណ្តុះបណ្តាល FFS → ទំព័រ 48~63

## លក្ខណៈសាលារៀនស្រែកសិករអនុវត្តដោយគម្រោងAPPP (1)

### ❖ វគ្គបណ្តុះបណ្តាលស្តីពីបច្ចេកទេសផ្សព្វផ្សាយកសិកម្ម

វគ្គបណ្តុះបណ្តាលបច្ចេកទេសសាលារៀនស្រែកសិកររបស់គម្រោងAPPPមានគោលបំណងបង្កើតក្រុមកសិករស្នូលដើម្បីពង្រីកការយល់ដឹង និងការអនុវត្តន៍របស់កសិករក្នុងតំបន់គោលដៅឲ្យបានចំនួនច្រើន។




សាលាស្រែកសិករលើកទី១- បណ្តុះបណ្តាលក្រុមកសិករបង្គោលដើម្បីពង្រីកការបណ្តុះបណ្តាលឲ្យមានការសាយភាយបន្ត

1 x 10=10

កំរិតទី២

10 x 10=100

កំរិតទី៣

10 x 10 x 10=1000.....

DF: កសិករបង្ហាញ
PF: កសិករចូលរួម
OF: កសិករធម្មតា

<u>លក្ខណៈសាលារៀនស្រែកសិករអនុវត្តដោយគម្រោងAPPP(2)</u>

## ❖ ទ្រឹស្តី និងការអនុវត្តន៍ព្រមគ្នាទាំងអស់ក្នុងពេលតែមួយ (ទិដ្ឋភាពទូទៅ)

វគ្គបណ្តុះបណ្តាលបច្ចេកទេសសាលារៀនស្រែកសិករ(FFS)របស់គម្រោងAPPPរួមបញ្ចូលទាំង**ទ្រឹស្តី** និង**ការអនុវត្តន៍**ដែលអាចឲ្យកសិករចូលរួម យកចំណេះដឹងដែលបានរៀនទៅអនុវត្តបានត្រឹមត្រូវក្នុងស្រែរបស់ខ្លួនបន្ទាប់ពីវគ្គបណ្តុះបណ្តាល។

### ការរៀបចំវគ្គបណ្តុះបណ្តាលFFSរបស់គម្រោងAPPPដល់កសិករដែលដាំដុះដំណាំស្រូវ



មន្ត្រី PDA* កំពុងពន្យល់ទ្រឹស្តីដល់កសិករដោយប្រើប្រាស់តារាងក្រាហ្វិក



មន្ត្រីផ្សព្វផ្សាយណែនាំពីរបៀបស្ទូងតាមបន្ទាត់



កសិករអនុវត្តបច្ចេកទេសស្ទូងជាជួរទៅលើស្រែរបស់ពួកគាត់ផ្ទាល់

**ការឆ្លុះបញ្ចាំង& រៀនសូត្រដោយខ្លួនឯង**



ក្នុងមួយវគ្គ រៀនទ្រឹស្តី និងអនុវត្ត (កន្លះថ្ងៃ) → អនុវត្តចំណេះដឹងដែលបានរៀនក្នុងស្រែផ្ទាល់ខ្លួន (គ្រប់ដំណាក់កាល) → ទទួលបានប្រសិទ្ធភាពនៃបទពិសោធន៍ (គ្រប់រដូវ)

* PDA: មន្ទីរកសិកម្មខេត្ត

## ❖ វិធីសាស្រ្តកសិករមជ្ឈមណ្ឌល

កសិករគឺជាអ្នកគ្រប់គ្រងកសិដ្ឋានផ្ទាល់ដូច្នេះហើយកសិករគឺត្រូវមានសមត្ថភាពក្នុងការគិត និងការសំរេចដោយខ្លួនឯងផ្ទាល់ដើម្បីទទួលបានលទ្ធផលជោគជ័យពីប្រាក់ចំណូលកសិកម្ម។ សមត្ថភាពកសិករប្រភេទនេះមិនអាចទទួលបានតាមរយៈវគ្គបណ្តុះបណ្តាលណាដែលមិនមានភាពច្បាស់លាស់បានទេ។ ឥរិយាបថឆ្ពោះទៅរកកសិករត្រូវតែមានភាពជាក់ស្តែង និងស្និតស្នាលរួមជាមួយការជំរុញលើកទឹកចិត្ត និងការគោរពដើម្បីជំរុញឱ្យពួកគាត់មានការផ្តួចផ្តើម និងទំនួលខុសត្រូវ។

### ទំនាក់ទំនងមួយផ្លូវ




ផ្តោតតែលើស្ថានភាពបញ្ហាតែប៉ុណ្ណោះ ហើយមិនយកចិត្តទុកដាក់ចំពោះកសិករ។



### ទំនាក់ទំនងពីរផ្លូវ (ការចែករំលែកបទពិសោធន៍)




កសិករត្រូវបានយកចិត្តទុកដាក់ជាពិសេស និងជំរុញលើកទឹកចិត្តឱ្យពួកគាត់មានការចាប់ផ្តើម និងទទួលខុសត្រូវដោយខ្លួនឯងផ្ទាល់។

## ទិដ្ឋភាពទូទៅនៃវគ្គបណ្តុះបណ្តាល និងការទទួលយកបច្ចេកទេស (1)

### ❖ អនុវត្តចំណេះដឹងស្របពេលនិងដំណាក់កាលលូតលាស់របស់ស្រូវ

វគ្គបណ្តុះបណ្តាលទាំងប្រាំបានបញ្ចូលការណែនាំបច្ចេកទេសដូចជា ការជ្រើសរើសពូជ ការរៀបចំថ្នាលសំណាប ការស្ទូងជាជួរ ឬ អូសពង្រោះដោយឧបករណ៍ត្រាំស៊ីឌ័រ ការដាក់ជីបំប៉ននិងការគ្រប់គ្រងមុនពេលប្រមូលផល។



# ទិដ្ឋភាពទូទៅនៃវគ្គបណ្តុះបណ្តាល និងការទទួលយកបច្ចេកទេស(2)

## ❖ ការទទួលយកបច្ចេកទេស(1)

ចំណុចខាងក្រោមគឺត្រូវបានប្រើជាការសន្ទតនៃការទទួលយកបច្ចេកទេសដែលជាទិដ្ឋភាពចាំបាច់សម្រាប់ភាពប្រសើរឡើងរវាងវិធីសាស្ត្រសាមញ្ញតាមទម្លាប់ និងបច្ចេកទេសតាមរយៈសាលារៀនស្រែកសិករ(FFS)ដែលអនុវត្តដោយគម្រោង APPP ក្នុងកំឡុងពេលប្រតិបត្តិការរបស់គម្រោង។

| ទិដ្ឋភាព | វិធីសាស្ត្រសាមញ្ញតាមទម្លាប់ | វិធីសាស្ត្រដាំដុះដំណាំស្រូវតាមរយៈបច្ចេកទេសFFS របស់គម្រោងAPPP | គោលបំណង |
|---|---|---|---|
| ប្រភពពូជ | កសិករមួយចំនួនបានដាំដុះដំណាំស្រូវរួច ហើយរក្សាស្រូវទុកមួយចំនួនដើម្បីធ្វើពូជ នៅរដូវដាំដុះបន្ទាប់។ | ស្រូវពូជដែលមានភាពសុទ្ធខ្ពស់គឺត្រូវបានប្រើដើម្បីផលិតពូជ សុទ្ធអនុញ្ញាត ហើយត្រូវបានប្រើប្រាស់នៅក្នុងតំបន់គោលដៅ របស់គម្រោង APPP។ | ដើម្បីលើកកម្ពស់ដល់ការយល់ដឹងឆ្ពោះ ទៅរកការប្រើប្រាស់ពូជមានគុណភាពខ្ពស់។ |
| ការជ្រើសរើសពូជ | គ្មានការជ្រើសរើសពូជ | មុនពេលសាបគ្រាប់ពូជត្រូវបានជ្រើសរើស និងលាងសំលាប់ មេរោគដោយទឹកក្តៅត្រឹម៦០អង្សា។ | ដើម្បីសំរេចបានអត្រាដំណុះខ្ពស់ និង ការពារជម្ងឺដែលជាប់មកជាមួយនិងគ្រាប់ពូជ |
| រងសំណាប | ថ្នាលសំណាបមិនបានលើកជារងហើយ ទុកសំណាបឲ្យមានអាយុវែងរួចកាត់ស្លឹក មុនពេលយកទៅស្ទូង (អាចយល់បានខ្លះ ថាវាអាចជាវិធានការប្រឆាំងនិងបញ្ហាទឹក ទាំងរាំងស្ងួត និងទឹកជំនន់)។ | លើករងដោយរៀបចំលាយជាមួយផ្សូងអង្កាម និងជីកំប៉ុស្ដិ៍ ប្រសិនបើមាន។ ផ្សូងអង្កាមគឺត្រូវបានប្រើដើម្បីធ្វើឲ្យសំណាប ងាយស្រួលចាប់ឫស និងរងការបំផ្លាញតិចដល់ឫសសំណាប។ ប្រើសំណាបដែលមានអាយុត្រឹម 21 ថ្ងៃ (ដំណាក់កាលស្លឹក ៣ –៤) ដើម្បីស្ទូង។ | ដើម្បីឲ្យសំណាបលូតលាស់ល្អដោយពុំ មានការបំផ្លាញស្លឹកនិងឫសរបស់វានៅ ក្នុងរយៈពេលលូតលាស់។ |
| ការរៀបចំដី | ការរៀបចំផ្ទៃដីមិនបានស្មើល្អដោយមិន បានយកចិត្តទុកដាក់កៀរពង្រាបនិងការ បែងចែកទឹកបានសព្វល្អ។ | ផ្ទៃដីរៀបចំស្មើល្អដោយមានការយកចិត្តទុកដាក់ក្នុងការកៀរ ពង្រាបដី និងបែងចែកទឹកបានសព្វល្អ ដើម្បីឱ្យស្រូវលូតលាស់ បានស្មើល្អ។ | ដើម្បីសម្រេចបានផ្ទៃដីរាបស្មើល្អដោយ ការកៀរពង្រាបបានត្រឹមត្រូវដែលបង្កឲ្យ មានលក្ខណៈងាយស្រួលក្នុងការគ្រប់គ្រង ទឹក និងស្មៅចង្រៃ។ |

## ❖ ការទទួលយកបច្ចេកទេស(2)

ចំណុចខាងក្រោមគឺត្រូវបានប្រើជាការសន្មតនៃការទទួលយកបច្ចេកទេសដែលជាទិដ្ឋភាពចាំបាច់សម្រាប់ភាពប្រសើរឡើងរវាងវិធីសាស្ត្រសាមញ្ញតាមទម្លាប់ និងបច្ចេកទេសតាមរយៈសាលារៀនស្រែកសិករ( FFS)ដែល អនុវត្តដោយគម្រោង APPP ក្នុងកំឡុងពេលប្រតិបត្តការរបស់គម្រោង។

| ទិដ្ឋភាព | វិធីសាស្ត្រសាមញ្ញតាមទម្លាប់ | វិធីសាស្ត្រដាំដុះដំណាំស្រូវតាមរយៈបច្ចេកទេសFFS របស់គម្រោងAPPP | គោលបំណង |
|---|---|---|---|
| ការស្ទូង | ស្ទូងតាមទម្លាប់ដោយសំណាបអាយុច្រើន ស្ទូងគ្មានជួរហើយច្រើនដើមក្នុងមួយគុម្ព(5-10ដើមក្នុងមួយគុម្ព)។ | ស្ទូងជាជួរដោយប្រើសំណាបតិច (2-3)ដើមក្នុងមួយគុម្ព។ | ដើម្បីសម្រេចបានប្រសិទ្ធភាពនៃការដាំដុះឲ្យសំណាបលូតលាស់បានល្អ។ |
| ការព្រោះ | ព្រោះដោយដៃហើយប្រើពូជដែលមានអត្រាដំណុះទាប និងស្រូវស្កូតហើយប្រើប្រាស់អស់បរិមាណពូជច្រើនក្នុងមួយរដូវ។ | ព្រោះដោយប្រើឧបករណ៍ត្រាំស៊ីឌ័រត្រូវបានជំរុញឲ្យប្រើប្រាស់យ៉ាងសកម្មសម្រាប់ស្រែដែលរំពឹងលើទឹកភ្លៀង ឬក៏ស្រែដែលមានប្រភពទឹកសម្រាប់ស្រោចស្រប់។ | ដើម្បីធ្វើឲ្យផលិតភាពល្អប្រសើរឡើងតាមរយៈការព្រោះជាជួរដោយធ្វើឲ្យដង់ស៊ីតេទាបសំណាបលូតលាស់បានល្អ។ |
| ការដាក់ជីបំប៉ន | គ្មានពេលវេលា ប្រភេទ និងចំនួនជីច្បាស់លាស់គឺប្រើប្រាស់តាមការយល់ឃើញ។ | លក្ខណៈសាមញ្ញ និងមានស្តង់ដាច្បាស់លាស់ក្នុងការប្រើប្រាស់ជីដោយរួមបញ្ចូលទាំងការណែនាំនូវពេលវេលាសមស្របសម្រាប់ការប្រើប្រាស់ជីផងដែរ។ | ដើម្បីធ្វើឲ្យការប្រើប្រាស់ជីមានប្រសិទ្ធភាពក្នុងការជំរុញការលូតលាស់របស់ស្រូវ។ |
| ការធ្វើស្មៅ | ការធ្វើស្មៅដោយដៃគឺមានការលំបាកដោយសារតែផ្ទៃដីធំ ឬក៏ខ្វះកំលាំងពលកម្ម។ ដូច្នេះហើយថ្នាំកំចាត់ស្មៅគឺត្រូវប្រើជាញឹកញាប់។ | ការរៀបចំដីបានល្អ និងគ្រប់គ្រងទឹកបានត្រឹមត្រូវអាចកាត់បន្ថយការលូតលាស់របស់ស្មៅនិងធ្វើឲ្យស្រូវលូតលាស់បានល្អ។ | ដើម្បីឲ្យយល់ដឹងអំពីសារៈសំខាន់នៃការរៀបចំដីក៏ដូចជាការគ្រប់គ្រងទឹកសម្រាប់វិធានការចំពោះស្មៅ។ |
| ការគ្រប់គ្រងមុនពេលប្រមូលផល | គ្មានការយកចិត្តទុកដាក់។ | ដើម្បីកែលម្អគុណភាពស្រូវដែលវាអាចប៉ះពាល់ដល់តម្លៃលក់ហើយបច្ចេកទេសមួយចំនួនដូចជាការដកពូជលាយ និងការពារចំពោះស្រូវដួលដើមគឺត្រូវបានអនុវត្តន៍នៅក្នុងដំណាក់កាលនេះ។ | ដើម្បីថែរក្សាស្ថានភាពស្រូវឲ្យល្អរហូតដល់ពេលប្រមូលផល។ |


វិធីសាស្ត្រជ្រើសរើសពូជ
(ជំហាន១)
JICA

## ❖ ការជ្រើសរើសពូជ និងការលាងសំលាប់មេរោគ

### គោលបំណង

- ញែកពូជដែលមានគុណភាពអន់ចេញ
- លាងសំលាបមេរោគដើម្បីការពារជម្ងឺ និងកក្លាចផ្សេងៗ

### អ្វីដែលត្រូវរៀបចំ

1. ពូជ
2. ថង់ស្បៃ
3. ទែម៉ូម៉ែត្រ
4. អំបិលឬជីអ៊ុយរ៉េ
5. ស៊ុតស្រស់
6. ការធុនប្លាស្ទិក
7. ជញ្ជីង
8. ធុង
9. ទឹក
10. អុស

### ពេលដែលត្រូវធ្វើ

- ៣-៤ថ្ងៃ ដល់ពីរ ឬ បីសប្តាហ៍មុនពេលសាប

### វិធីធ្វើ

**ផ្នែកពន្យល់ទ្រឹស្តី (30-60 នាទី):**

1) ត្រួតពិនិត្យវត្តមានដើម្បីបង្កើនប្រសិទ្ធភាពនៃការបង្រៀន
2) ពន្យល់ពីគោលបំណង និងគុណប្រយោជន៍នៃបច្ចេកទេស

ដំណាំស្រូវចាប់ផ្តើមអភិវឌ្ឍពីគ្រាប់ពូជ ដូច្នេះការទទួលបានគ្រាប់ពូជដែលមានគុណភាពគឺជារឿងសំខាន់ដែលត្រូវយកចិត្តទុកដាក់ដំបូងគេ។ បន្ថែមលើនេះទៅទៀតការអនុវត្តវិធីសាស្ត្រប្រព្រឹត្តកម្មពូជដូចជាការជ្រើសរើសពូជ និងការលាងសំលាប់មេរោគវាក៏អាចជួយឲ្យមានផលិតភាពខ្ពស់ផងដែរ។

3) គោលការបច្ចេកទេសរួមបញ្ចូលទាំងវិធីសាស្ត្រអណ្តែត និងវិធីសាស្ត្រកម្តៅ

❖ វិធីសាស្ត្រអណ្តែតប្រើសម្រាប់ជ្រើសរើសពូជដែលមានគុណភាពដោយការប្រើប្រាស់ទំនាញសូលុយស្យុងជាក់លាក់
- ✓ របៀបធ្វើឲ្យសូលុយស្យុងអណ្តែតដើម្បីញែកពូជ
- ✓ វិធីត្រួតពិនិត្យកំរិតទំនាញជាក់លាក់ដោយប្រើស៊ុតស្រស់,
- ✓ អត្ថន័យនៃគ្រាប់ពូជអណ្តែត និងគ្រាប់មិនអណ្តែត.

❖ វិធីសាស្ត្រកម្តៅសម្រាប់សំលាប់មេរោគពូជ
- ✓ អត្ថន័យនៃការលាងសំលាប់មេរោគដោយទឹកក្តៅ
- ✓ សារ:សំខាន់នៃកំរិតសីតុណ្ហភាព 60℃ និងរយ:ពេល 10នាទី។

**ផ្នែកអនុវត្តជាក់ស្តែង (ប្រហែល 60នាទី ជាមួយការរៀបចំយ៉ាងត្រឹមត្រូវ):**

1) ដាក់ពូជចូលក្នុងថង់ស្បៃ
2) រៀបចង្ក្រាន និងដាំទឹកទុកមុន(សន្សំពេលវេលា)
3) វាស់កំរិតអំបិល និងជីអ៊ុយរ៉េដើម្បីរៀបចំសូលុយស្យុងអណ្តែត
4) អនុវត្តការជ្រើសរើសពូជមុន(យកពូជអណ្តែតចេញ ហើយដាក់ពូជដែលអត់អណ្តែតចូលទៅក្នុងថង់ស្បៃរួចលាងសំអាតឲ្យសព្វក្នុងទឹក)
5) អនុវត្តការលាងសំលាប់មេរោគ (ពូជដែលបានជ្រើសរើស) ដោយទឹកក្តៅ(រក្សាសីតុណ្ហភាពត្រឹម 60 ℃ រយ:ពេល 10នាទីគត់)
6) លាងពូជដែលស្រស់រួចដោយទឹកត្រជាក់ភ្លាមៗដើម្បីបញ្ចៀសភាពក្តៅខ្លាំងអាចធ្វើខូចគ្រាប់ស្រូវ
7) រក្សាពូជដែលធ្វើការជ្រើសរើសរួចទុកឲ្យស្ងួត ឬផ្អាប់ឲ្យដុះ

**ផ្នែកឆ្លុះបញ្ចាំងការបណ្តុះបណ្តាល (10 នាទី): ឆ្លុះបញ្ចាំងមេរៀនដែលបានរៀនរួច (ពីទ្រឹស្តី និងការអនុវត្ត)**

## ❖ ការជ្រើសរើសពូជ

### ជំហានទី1. ប៉ាន់ប្រមាណចំនួនដើម្បីធ្វើសូលុយស្យុងអណ្តែតដោយកំរិតទំនាញជាក់លាក់

| សម្ភារៈសូលុយស្យុង / កំរិតនៃថាមពលអណ្តែត | ទឹក | ក្នុងករណីអំបិល | ក្នុងករណីជីអ៊ុយរ៉េ |
|---|---|---|---|
| គ្មានទំនាញច្បាស់លាស់: (គ្មានថាមពលអណ្តែត, អណ្តែតតែគ្រាប់ដែលស្រាលប៉ុណ្ណោះ) | 10 លីត្រ | 0 គ.ក | 0 គ.ក |
| កំរិតទំនាញជាក់លាក់ទាប: (ថាមពលអណ្តែតខ្សោយ, គ្រាប់ដែលអត់ពេញមួយចំនួនអាចអណ្តែត) | 10 លីត្រ | 1.1 គ.ក | 2.5 គ.ក |
| កំរិតទំនាញជាក់លាក់ខ្ពស់: (ថាមពលអណ្តែតខ្ពស់, គ្រាប់ដែលអត់ពេញភាគច្រើនអាចអណ្តែត ) | 10 លីត្រ | 2 គ.ក | 5.0 គ.ក |

### ជំហានទី2. របៀបប៉ាន់ស្មានកំរិតជាក់លាក់នៃទំនាញដោយបណ្តែតស៊ុត




### ជំហានទី3. សមាសធាតុនៃសូលុយស្យុងអណ្តែតដើម្បីជ្រើសរើសពូជដែលមានគុណភាព




### ជំហានទី៤. លាងសំអាតអំបិល ឬជីអ៊ុយរ៉េចេញដោយទឹកស្អាតដើម្បីបញ្ចៀសនូវអត្រាដំណុះទាប



### ជំហានទី5. ដាក់ពូជចូលក្នុងថង់ស្បៃ



ដំណើរការនៃការលាងសំលាប់មេរោគដោយទឹកក្តៅ

## ❖ ការលាងសំលាប់មេរោគលើគ្រាប់ពូជ

ដំណើរការជ្រើសរើសពូជដោយវិធីសាស្រ្តអណ្តែត

1

**ជំហានទី0. ពូជដែលបានជ្រើសរើសរួចគឺច្រកដាក់ក្នុងថង់ស្បៃ**



2

**ជំហានទី1. បង្កាត់ភ្លើង**



3

**ជំហានទី2. ត្រួតពិនិត្យសីតុណ្ហភាព**




4

**ជំហានទី3. ការលាងសំលាប់មេរោគ**




រក្សាសីតុណ្ហភាពត្រឹម 60°C ដោយការកែតម្រូវភ្លើង និងទឹក

ត្រាំត្រឹមរយៈពេល 10 នាទីដើម្បីកុំឲ្យក្តៅជ្រុល

ក្រលែងថង់ស្បៃឲ្យសព្វស្មើដើម្បីឲ្យកម្តៅចូលសំលាប់មេរោគបានសព្វ

កុំឲ្យថង់ស្បៃប៉ះបាតឆ្នាំងកុំឲ្យខូចខាតដោយសារកម្តៅខ្លាំង

5

**ជំហានទី4. លាងជម្រះដោយទឹកត្រជាក់**

ក្រលែងថង់ស្បៃដើម្បីឲ្យកម្តៅចេញកុំឲ្យមានការបំផ្លាញដោយសារកម្តៅទឹកដល់គ្រាប់ពូជ។ក្រលែងវាឲ្យញាប់។



6

ចាប់ផ្តើមដំណើរការផ្អាប់សម្រាប់ដំណុះក្នុងករណីយកទៅសាប និងព្រោះ ឬហាលឲ្យស្ងួតរួចរក្សាទុកនៅកន្លែងស្អាត និងស្ងួតរហូតដល់ពេលដាំដុះ

## ❖ ផ្អាប់សម្រាប់ដំណុះ

### គោលបំណង

- ➢ ដើម្បីធ្វើឲ្យសំណាបលូតលាស់ព្រមគ្នា
- ➢ ភាពស្មើគ្នានៃដំណុះធ្វើឲ្យសំណាបដុះព្រមគ្នា នាំឲ្យការលូតលាស់មានប្រសិទ្ធភាព

### អ្វីដែលត្រូវរៀបចំ

1. ការជ្រើសរើសពូជ
2. ថង់ស្បៃ
3. ទែម៉ូម៉ែត្រ
4. កាធុនផ្លាស្ទិក
5. ទឹក
6. ការ៉ុង

### ពេលវេលាត្រូវធ្វើ

- ➢ 2-3 ថ្ងៃមុនពេលសាប ឬព្រោះ

### វិធីធ្វើ

**ផ្នែកពន្យល់ទ្រឹស្តី (30នាទី):**

1) ត្រួតពិនិត្យវត្តមានដើម្បីបង្កើនប្រសិទ្ធភាពនៃការបង្រៀន
2) ពន្យល់ពីគោលបំណង និងគុណប្រយោជន៍នៃបច្ចេកទេស

ដំណុះនៃគ្រាប់ពូជគឺជាចំណុចចាប់ផ្តើមដំបូងដើម្បីសម្រេចបានការលូតលាស់ព្រមគ្នាដែលអាចប៉ះពាល់គ្រប់មធ្យោបាយរហូតដល់ពេលប្រមូលផល។ ដូច្នេះសូមយកចិត្តទុកដាក់ជាដំបូងដល់លក្ខខណ្ឌដែលអាចធ្វើឲ្យដំណុះដុះព្រមគ្នាក្នុងពេលតែមួយគួរតែត្រូវបានសាកល្បង។

1) គោលការណ៍នៃបច្ចេកទេសរួមបញ្ចូលទាំងវិធីសាស្ត្រត្រាំ និងផ្អាប់ពូជ

❖ ត្រាំ24-48 ម៉ោងនៅក្នុងទឹកស្អាតដែលមានសីតុណ្ហភាពធម្មតា (20-25 ℃)

- ✓ អត្ថន័យនៃការត្រាំក្នុងទឹកគឺដើម្បីស្រូបយកទឹកឱ្យបានគ្រប់គ្រាន់ដើម្បីបង្កឱ្យមានដំណុះ
- ✓ សីតុណ្ហភាពទឹកមិនចាំបាច់ខ្ពស់ពេកទេ (20-25 ℃ ប្រហែលគ្រប់គ្រាន) ដើម្បីបញ្ចៀសបានការដុះមិនស្មើរគ្នា។

❖ ផ្អាប់ទុក24ម៉ោងក្នុងសីតុណ្ហភាពប្រហែល30℃ ឬច្រើនជាង

- ✓ អត្ថន័យ និងគោលបំណងនៃការផ្អាប់ដោយសីតុណ្ហភាពខ្ពស់គឺដើម្បីចាប់ផ្តើមឲ្យដំណុះដុះក្នុងលក្ខខណ្ឌព្រមគ្នា
- ✓ កម្រិតនៃដំណុះដ៏ល្អបំផុតសម្រាប់ការសាបព្រោះគ្រាប់ពូជគឺត្រូវទុកឲ្យដុះពន្លកចេញ។ នេះគឺដើម្បីកាត់បន្ថយការខូចខាតពេលចាក់ឬស។

**ផ្នែកអនុវត្តន៍ជាក់ស្តែង (ប្រហែល30នាទី ដោយការរៀបចំយ៉ាងត្រឹមត្រូវ):**

1) ពូជគឺត្រូវដាក់ក្នុងថង់ស្បៃ (ប្រសិនបើមាន) ដើម្បីងាយស្រួលក្នុងការកាន់យួរ
2) ត្រាំពូជក្នុងទឹកដែលមានសីតុណ្ហភាពធម្មតា (20-25 ℃)
3) ក្រឡែងថងស្បៃ ឬកូរពូជឲ្យសព្វដើម្បីឲ្យទឹកចូលបានគ្រប់កន្លែង
4) បន្ទាប់ពីត្រាំទុករយៈពេល 24ម៉ោង (រដូវក្តៅ), ឬ 48 ម៉ោង (រដូវត្រជាក់), រួចស្រង់ពូជចេញពីទឹក ហើយច្រកទុកវានៅក្នុងការ៉ុងប្រសិនបើការ៉ុងជីលាងវាឲ្យស្អាតរួចផ្អាប់ទុករយៈពេល 24 ម៉ោង,
5) សីតុណ្ហភាពជុំវិញគួរតែមានស្ថេរភាពប្រហែល 30℃ ឬខ្ពស់ដើម្បីឲ្យដំណុះស្មើរគ្នា
6) ត្រួតពិនិត្យមើលលក្ខណៈរបស់គ្រាប់ឲ្យដុះចេញពន្លក,
7) សំដិលពូជឲ្យស្ងួតល្មមសម្រាប់សាប ឬព្រោះ។

**ផ្នែកឆ្លុះបញ្ចាំងការបណ្តុះបណ្តាល (10 នាទី): ឆ្លុះបញ្ចាំងមេរៀនដែលបានរៀនរួច (ពីទ្រឹស្តី និងការអនុវត្ត)**

## ❖ ការផ្អាប់សម្រាប់ដំណុះ

**ជំហានទី1: ទុកពូជឲ្យស្រូបទឹកបានរយៈពេល 1-2 ថ្ងៃ ដើម្បីពញ្ញាក់ដំណេកពូជ**

**ជំហានទី2:ការផ្អាប់ដើម្បីដំណុះក្រោមសីតុណ្ហភាពខ្ពស់ (30-35℃)**



# តើកំរិតដំណុះមួយណាល្អប្រសើរជាង?

| ពូជដែលលដុះពន្លកវែងពេក<br>(ផ្អាប់ទុករយៈពេលយូរបន្ទាប់ពីដំណុះ) | ដំណាក់កាលនៃពន្លកបានត្រឹមត្រូវ<br>(មានដុះពន្លកចេញ) |
|---|---|
|  |  |
| ✓ ខូចខាតរូបរាងដូចជាដាច់ឬស និងបាក់បែកបានយ៉ាងងាយ<br>✓ មិនល្អសម្រាប់ការព្រោះដោយឧបករណ៍ត្រាំស៊ីតឌ័រព្រោះវាអាចស្ទះ<br>✓ ដើមសំណាបមិនរឹងមាំដោយសារគ្រាប់ពូជបាត់បង់សារធាតុចិញ្ចឹម<br>✓ សាបមិនបានស្មើល្អ | ✓ ងាយស្រួលចាប់កាន់ហើយឱកាសក្នុងការខូចខាតរូបរាងមានតិច<br>✓ អត្រាដំណុះអាចត្រួតពិនិត្យបានយ៉ាងងាយដោយការអង្កេត និងរាប់<br>✓ សមស្របសម្រាប់ការព្រោះដោយឧបករណ៍ត្រាំស៊ីតឌ័រ<br>✓ សន្សំសំចៃពេលវេលា និងបញ្ចៀសបានការប៉ះពាល់សារធាតុចិញ្ចឹមរបស់គ្រាប់ពូជបានផងដែរ |

✓ ពូជដែលដុះពន្លកខ្លីជាមួយនិងអត្រាដំណុះខ្ពស់ជាង 85% មានលក្ខណៈងាយស្រួលក្នុងការអង្កេត និងរាប់ហើយសមស្របសម្រាប់ការលូតលាស់ជាងពូជដែលមានដំណុះវែងមិនស្មើគ្នា


វិធីសាស្ត្ររៀបចំថ្នាសំណាប
(ជំហាន ២)

## ❖ ការរៀបចំថ្នាលសំណាប (ថ្នាលសំណាបរដូវវស្សា)- អាយុសំណាបសម្រាប់ស្ទូង 21 ថ្ងៃ (3 សប្តាហ៍)

### គោលបំណង

➢ ដើម្បីឲ្យសំណាបលូតលាស់ស្មើរគ្នា និងរឹងមាំល្អ

### អ្វីដែលត្រូវរៀបចំ

1. រងសំណាប, ថ្នាលសំណាបដែលមានប្រភពទឹក និងផ្លូវទឹកចេញចូល
2. ឧបករណ៍រៀបចំដី
3. ធ្យូងអង្កាម
4. ជីទ្រាប់បាត
5. ពូជដែលបានផ្អាប់

### ពេលដែលត្រូវធ្វើ

➢ 20-25 ថ្ងៃមុនពេលស្ទូងក្នុងករណីពូជស្រូវកណ្តាល

### វិធីធ្វើ

**ពន្យល់ផ្នែកទ្រឹស្តី (30នាទី):**

1) គ្រូតពិនិត្យវត្តមានដើម្បីបង្កើនប្រសិទ្ធភាពនៃការបង្រៀន

២) ពន្យល់ពីគោលបំណង និងគុណប្រយោជន៍នៃបច្ចេកទេស

គ្រាប់ពូជដែលបានជ្រើសរើស សំលាប់មេរោគ និងដុះពន្លកត្រឹមត្រូវ គឺត្រូវបានយកទៅប្រើសម្រាប់សាបលើថ្នាលដែលបានរៀបចំយ៉ាងត្រឹមត្រូវដែលអាចធានាការលូតលាស់ល្អ និងរឹងមាំនៅក្នុងដំណាក់កាលដំបូងរបស់សំណាប ដូច្នេះបន្ទាប់ពីសន្ទូងស្រូវនិងបែកគុម្ពល្អឡើងវិញ។

3) តម្រូវការចាំបាច់ដើម្បីសម្រេចបានលទ្ធផលល្អក្នុងការធ្វើឲ្យសំណាបក្នុងថ្នាលលូតលាស់បានល្អ

- ❖ ប្រភពទឹក: មានស្ថេរភាពក្នុងការផ្គត់ផ្គង់ទឹកដោយមានប្រភពទឹកគ្រប់គ្រាន
- ❖ ទំហំរងសំណាប: ក្រឡាផ្ទៃប្រហែល 1 (ថ្នាល) ប្រហែលទៅនឹងផ្ទៃដីស្រែ20ភាគរយ ក្នុងសមាមាត្រដែលត្រូវការ
- ❖ រាងរបស់រងសំណាប: លើកជារាងចតុកោណព្នាយ
- ❖ ចំនួនពូជក្នុង 1 ហិចតា (ដង់ស៊ីតេ): ពូជប្រហែល40-50គ.ក ក្នុងផ្ទៃដីថ្នាល 500 m²
- ❖ ការដាក់ជីទ្រាប់បាត: ដាក់ជី DAP ប្រហែល 10ក្រក្នុងទំហំផ្ទៃដី 1m x 1m (1 m²), 5គកក្នុងករណីទំហំផ្ទៃដី 500 m²
- ❖ ការប្រើធ្យូងអង្កាម: ធ្យូងបានកែប្រែស្ថានភាពគុណភាពដីដើម្បីការលូតលាស់ និងសំណាបងាយស្រួលចាប់ឫសនិងកាត់បន្ថយបានការបំផ្លាញឫស
- ❖ រយ:ពេលលូតលាស់របស់សំណាប: លូតលាស់រហូតដល់ 21ថ្ងៃ ឬ 3 សប្តាហ៍មុនពេលយកទៅស្ទូង

**ផ្នែកអនុវត្តន៍ជាក់ស្តែង (ប្រហែល30នាទី ដោយការរៀបចំយ៉ាងត្រឹមត្រូវទុកជាមុន):**

1) រៀបចំដី 2-3 ថ្ងៃមុនពេលអនុវត្ត
2) លើករងកម្ពស់5-10 ស.ម ដោយឧបករណ៍ ឬដៃ
3) លាយជីកំប៉ុសជាមួយជីទ្រាប់បាតរួចបាច់លើផ្ទៃរង
4) រាយធ្យូងអង្កាមឲ្យសព្វស្មើរលើផ្ទៃរង
5) កៀរពង្រាប និងធ្វើឲ្យផ្ទៃរងរាបស្មើល្អ
6) សាបពូជក្នុងមួយ(1) ស្រទាប់ដោយមានកំរិតដង់ស៊ីតេត្រឹមត្រូវ (80 -100g/m²)
7) បាចធ្យូងអង្កាមមួយស្រទាប់ទៀតដើម្បីរក្សាសំណើម និងកុំឲ្យសត្វបក្សីមករើសស៊ីគ្រាប់ពូជ

**ផ្នែកឆ្លុះបញ្ចាំងការបណ្តុះបណ្តាល (10 នាទី): ឆ្លុះបញ្ចាំងមេរៀនដែលបានរៀនរួច (ពីទ្រឹស្តី និងការអនុវត្ត)**

## ❖ ការរៀបចំថ្នាលសំណាប (ថ្នាលសំណាបរដូវវស្សា)- អាយុសំណាបសម្រាប់ស្ទូង 21 ថ្ងៃ (3 សប្តាហ៍)



## ❖ ការរៀបចំថ្នាលសំណាប (ថ្នាលសំណាបរដូវវស្សា)- អាយុសំណាបសម្រាប់ស្ទូង 21 ថ្ងៃ (3 សប្តាហ៍)

[ការប៉ាន់ប្រមាណចំនួនពូជក្នុង 1 ហិចតា (100m x 100m) ក្នុងករណីស្ទូង 3 ដើមក្នុងមួយគុម្ព ក្នុងចន្លោះ20cm x 25cm]




1) ចាប់ផ្តើម: ៣ដើមក្នុងមួយគុម្ព ដូចគោលដៅដែលកំណត់

2) តើមានប៉ុន្មានគុម្ពក្នុងមួយហិចតា?:
10,000$m^2$/(20cm x 25 cm)=200,000 គុម្ព

3) តើត្រូវការសំណាបប៉ុន្មានក្នុងមួយហិចតា?:
200,000គុម្ព x 3 ដើម=600,000 ដើម

4) ដូច្នេះត្រូវការពូជប៉ុន្មានគ្រាប់?: 600,000គ្រាប់

5) ត្រូវនឹងប៉ុន្មានគីឡូក្រាម?: 100គ្រាប់≒3g (PRD)*
600,000/100 x 3g=18,000g=18kg

6) ចាត់ទុកថាអត្រាដំណុះ70%:
18kg/0.7=26kg

7) ចាត់ទុកថាអត្រារស់មានជីវិតរបស់សំណាប 70%:
18kg/0.7=37kg≒40kg/ហាត

<u>រូបភាពបង្ហាញពីសមាមាត្ររវាងថ្នាលសំណាប និងស្រែសន្ទូង</u>




ពូជប្រហែល 40 kg(80g/1 $m^2$)អាចគ្រប់គ្រាន់សម្រាប់សាបលើផ្ទៃថ្នាលសំណាប500 $m^2$ដើម្បីស្ទូងលើផ្ទៃដីមួយ(1) ហិចតា



* 100 គ្រាប់នៃពូជផ្ការំដួល (PRD) ត្រូវបានប៉ាន់ស្មានថាស្មើ 3g. ផ្អែកលើទិន្នន័យរបស់ CARDI



❖ ការរៀបចំថ្នាលសំណាប (ថ្នាលសំណាបរដូវវស្សា)– ប្រសិទ្ធភាពនៃធ្យូងអង្កាម
អង្កាមយកមកពីរោងម៉ាស៊ីន
ដុតឆេះ ទាំងស្រុង
ផេះ
✓ មានប្រសិទ្ធទាបលើប្រពន្ធលូតលាស់ឫស
✓ រក្សាសំណើមតិច
✓ ខ្យល់ចេញចូលទាប
✓ សារធាតុចិញ្ចឹមទាប
ការធ្វើកាបូនអង្កាម (ធ្យូង)
1) អុសដែលឆេះបានយូរ
2) ប្រាកដថាភ្លើងឆេះយ៉ាងខ្លាំង
3) យកបំពងផ្សែងមកគ្រប
4) យកអង្កាមមកគដាក់ជុំវិញឧបករណ៍ដុត
5) យកអង្កាមមកដាក់ពីលើផ្នែកដែលឆេះខ្មៅដើម្បីដុះបន្ត
6) វាស្មើរតែរួចរាល់
7) ប្រោះទឹកដើម្បីឲ្យត្រជាក់
8) ប្រោះលើបន្ថែមទៀតដើម្បីឲ្យត្រជាក់ រួចទុកឲ្យស្ងួត
ធ្យូងអង្កាម
✓ ដីទន់
✓ មានប្រសិទ្ធខ្ពស់លើប្រពន្ធលូតលាស់ឫស
✓ មានប្រសិទ្ធិភាពខ្ពស់ក្នុងការរក្សាសំណើម
✓ ខ្យល់ចេញចូលខ្ពស់
✓ សម្បូរសារធាតុចិញ្ចឹម


វិធីសាស្រ្តស្ទូងជាជួរ
(ជំហាន៣)

# ❖ វិធីសាស្រ្តស្ទូងជាជួរ

## គោលបំណង

➢ ដើម្បីស្ទូងសំណាបទៅក្នុងស្រែជាជួរ

## អ្វីដែលត្រូវរៀបចំ

1. សំណាបដែលមានអាយុ 21ថ្ងៃ
2. ស្រែដែលមានទឹក និងកៀពង្រាបដីបានត្រឹមត្រូវ
3. ដាក់ជីទ្រាប់បាត
4. ខ្សែសម្រាប់ធ្វើជាបន្ទាតស្ទូងជួរមេ

## ពេលដែលត្រូវធ្វើ

➢ ការរៀបចំដីស្រែ: ពីបីថ្ងៃមុនពេលស្ទូង
➢ ការស្ទូង: ពេលដែលសំណាបមានអាយុ21ថ្ងៃ (ដំណាក់កាលមាន3-4ស្លឹក)

## វិធីធ្វើ

**ផ្នែកពន្យល់ទ្រឹស្តី (30-នាទី):**

1) ត្រួតពិនិត្យវត្តមានដើម្បីបង្កើនប្រសិទ្ធភាពនៃការបង្រៀន
2) ពន្យល់ពីគោលបំណង និងគុណប្រយោជន៍នៃបច្ចេកទេស

➢ ការស្ទូងជាជួរៈ លក្ខខណ្ឌនៃការលូតលាស់មានតុល្យភាពពីគុម្ពមួយទៅគុម្ពមួយដែលនាំឲ្យការលូតលាស់មានភាពស្មើគ្នា និងទទួលបានផលិតភាពខ្ពស់។
➢ ចន្លោះគុម្ពៈ ខ្យល់បរិសុទ្ធចេញចូលបានច្រើនបំផុត និងបរិស្ថានជុំវិញគុម្ពស្រូវល្អបំផុតសម្រាប់ការលូតលាស់ដោយសារស្រូវអាចទទួលបានពន្លឺព្រះអាទិត្យគ្រប់គ្រាន់សម្រាប់ធ្វើរស្មីសំយោគដើម្បីការរីកលូតលាស់រូបរាង។
➢ ការកំណត់ចំនួនដើមក្នុងមួយគុម្ពៈ ប្រសិទ្ធភាពនៃការប្រើប្រាស់សារធាតុដែលមាននៅក្នុងដី និងទឹកដោយដើមស្រូវនិមួយៗដើម្បីការលូតលាស់ល្អ។
➢ ការគ្រប់គ្រងស្មៅ: ដក ឬគ្រប់គ្រងស្មៅដើម្បីឲ្យបាត់បង់សារធាតុចិញ្ចឹមតិចបំផុតដែលអាចប្រើដោយដំណាំស្រូវជំនួសវិញ។

3) មូលដ្ឋានចាំបាច់ដើម្បីសម្រេចបានលទ្ធផលល្អក្នុងវិធីសាស្រ្តស្ទូងជាជួរ

❖ សារៈសំខាន់នៃការរៀបចំដី(ស្រែ): ការរៀបចំដីបានត្រឹមត្រូវគឺពិតជាមានសារៈសំខាន់ក្នុងការបង្កើតឲ្យមានភាពស្មើគ្នានៃដំណាំស្រូវដើម្បីទទួលបានទិន្នផលខ្ពស់បំផុត។
❖ ការគ្រប់គ្រងទឹក: គួរតែរក្សាកំរិតទឹកគ្រាប់គ្រាន់នៅក្នុងស្រែដោយការគ្រប់គ្រងការផ្គត់ផ្គង់ និងការបញ្ចេញបញ្ចូលទឹក។
❖ ចន្លោះគុម្ព (គម្លាត): 20cm(គុម្ព) x 25cm(ជួរ)ត្រូវបានណែនាំ។
❖ ចំនួនដើមក្នុងមួយគុម្ពៈ 2-3 ដើមក្នុងមួយគុម្ពត្រូវបានណែនាំ។
❖ ជីទ្រាប់បាត: ប្រើជីD.A.P 40-50 kg ក្នុង 1 ហិចតា។

**ផ្នែកអនុវត្តជាក់ស្តែង (ប្រហែល 30-60 នាទីដោយមានការរៀបចំយ៉ាងត្រឹមត្រូវទុកជាមុន):**

1) រៀបចំដី 2-3 ថ្ងៃមុនពេលអនុវត្តន៍
2) ដក និងស្ទូងទៅក្នុងស្រែដោយមានការប្រុងប្រយ័ត្ន
3) កំណត់បន្ទាត់ជួរមេដោយប្រើខ្សែ
4) ស្ទូងជួរមេជាបន្ទាត់នាំមុខមុន
5) ស្ទូងបំពេញក្នុងជួរមេដោយស្ទូងតាមជួរមេ

**ផ្នែកឆ្លុះបញ្ចាំការបណ្តុះបណ្តាល (10 នាទី): ឆ្លុះបញ្ចាំងមេរៀនដែលបានរៀនរួច (ពីទ្រឹស្តី និងការអនុវត្ត)**

## ❖ វិធីសាស្ត្រស្ទូងជាជួរ–"ការរៀបចំដី"

1. ភ្ជួរ → 2. រាស់ → 3. កៀរ → 4. កៀរពង្រាបចុងក្រោយ






សណ្ឋានដី & ទឹក



| | |
|---|---|
| រក្សាទឹក | សមត្ថភាពក្នុងការរក្សាទឹកបានខ្ពស់ជាងមុន |
| ការកៀរ | ការកៀរពង្រាបដីបានល្អអាចចែកចាយទឹកបានសព្វពេញស្រែ |
| ការគ្រប់គ្រងស្មៅ ពូជលាយ | ការភ្ជួរលប់ស្មៅ និងគ្រាប់ពូជដែលបានដាំដុះពីរដូវមុនទៅក្នុងដីរួចបញ្ចូលទឹក វាអាចរារាំងដល់ការលូតលាស់ទាំងស្មៅ និងពូជលាយផ្សេងៗបាន |
| ការលូតលាស់របស់ស្រូវ | ការរាស់ដីបំបែកបានល្អធ្វើឲ្យមានទឹកដក់ និងបំបែកសារធាតុចិញ្ចឹមក្នុងដី វាអាចបង្កើតបានជាបរិស្ថានល្អសម្រាប់ការលូតលាស់របស់សំណាបក្រោយពេលស្ទូង។ |

# ❖ វិធីសាស្ត្រស្ទូងជាជួរ - វិធីស្ទូងក្នុងជួរត្រង់






ខ្សែចងដោយខ្សែពណ៌ក្រហម ជាសញ្ញាសម្រាប់សម្គាល់ ចម្ងាយរវាងគុម្ពនិមួយៗ (សម្ភារៈសម្រាប់ស្ទូងជាជួរ)

1




2




3



## ❖ វិធីសាស្រ្តស្ទូងជាជួរ

[គុណប្រយោជន៍ដែលរំពឹងទុកពីវិធីសាស្រ្តស្ទូងជាជួរ]

“ការស្ទូងជាជួរត្រង់” អាចឲ្យខ្យល់បរិសុទ្ធចេញចូលបានជុំវិញគុម្ពស្រូវ ដែលវាអាចការពារបាននូវការកើតឡើងជម្ងឺផ្សេងៗ។

“ស្ទូងត្រឹមតែ 3ដើមក្នុងមួយគុម្ព” អាចបង្កើនសក្តានុពលនៃការលូតលាស់បែកគុម្ព និងចំនួនកំណាកំណើតគួរក្នុងមួយគុម្ពដែលនាំឲ្យទទួលបានទិន្នផលខ្ពស់។

ជួរត្រង់




“ចន្លោះគុម្ព 20 cm x 25 cm”អាចឲ្យស្រូវទទួលបានពន្លឺព្រះអាទិត្យគ្រប់គ្រាន់ដើម្បីបង្កើតថាមពលតាមរយៈការធ្វើរស្មីសំយោគដែលអាចធ្វើឲ្យស្រូវលូតលាស់លឿន។

“ចន្លោះគុម្ព (25cm) អាចដើរចូលបាន” អាចឲ្យមនុស្សចូលធ្វើស្មៅ និងដកពូជលាយក្នុងករណីចាំបាច់ ហើយស្មៅ និងពូជលាយត្រូវបានប្រទះឃើញ និងដកបានយ៉ាងងាយ។


វិធីសាស្ត្រអូសពង្រោះ
ដោយឧបករណ៍

# ❖ វិធីសាស្ត្រអូសពង្រោះដោយឧបករណ៍ (ព្រោះនៅក្នុងស្រែលើដីសើម)

## គោលបំណង

➢ ដើម្បីប្រើប្រាស់ឧបករណ៍ត្រាំស៊ីឌ័របានត្រឹមត្រូវក្នុងការកាត់បន្ថយថ្លៃដើមផលិត និងបង្កើនផលិតភាពដោយមិនចាំបាច់រៀបចំថ្នាលសំណាប និងស្ទូងជាជួរ

## អ្វីដែលត្រូវរៀបចំ

1. ឧបករណ៍ត្រាំស៊ីឌ័រ
2. ពូជដែលបានជ្រើសរើស
3. ការរៀបចំដីស្រែបានត្រឹមត្រូវ
4. ខ្សែសម្រាប់ធ្វើបន្ទាត់មេ

## ពេលដែលត្រូវធ្វើ

➢ បន្ទាប់ពីការរៀបចំស្រែរួច

## វិធីធ្វើ

**ផ្នែកពន្យល់ទ្រឹស្តី (30-នាទី):**

1) ត្រួតពិនិត្យវត្តមានដើម្បីបង្កើនប្រសិទ្ធភាពនៃការបង្រៀន

2) ពន្យល់ពីគោលបំណង និងគុណប្រយោជន៍នៃបច្ចេកទេស

រៀនពីគុណប្រយោជន៍ដោយការប្រៀបធៀបរវាងវិធីសាស្ត្រពង្រោះដោយឧបករណ៍ និងវិធីសាស្ត្រស្ទូងជាជួរ។

3) មូលដ្ឋានចាំបាច់ដើម្បីសម្រេចបានលទ្ធល្អក្នុងវិធីសាស្ត្រអូសពង្រោះដោយឧបករណ៍

- ❖ សារៈសំខាន់នៃការរៀបចំដី: ការរៀបចំដីបានល្អគឺនៅតែចាំបាច់ព្រោះការអូសពង្រោះគឺទាមទាឲ្យមានទឹកសព្វស្មើរដើម្បីគ្រប់គ្រស្មៅ។
- ❖ រកពេលវេលាដែលសមស្របសម្រាប់អូសពង្រោះ: ពេលចាប់ផ្តើមធ្លាក់ភ្លៀង និងប្រភពទឹកគឺត្រូវត្រួតពិនិត្យយ៉ាងយកចិត្តទុកដាក់ដើម្បីសម្រេចជ្រើសយកពេលអូសពង្រោះ។
- ❖ ការគ្រប់គ្រងស្មៅ: ការរៀបចំដីបានត្រឹមត្រូវគួបផ្សំនិងការគ្រប់គ្រងទឹកបានល្អក៏ដូចជាការរៀបចំប្រើប្រាស់ថ្នាំគីមី គឺត្រូវឲ្យមានការពិចារណា។
- ❖ ការថែរក្សាឧបករណ៍ត្រាំស៊ីឌ័រ: គួរតែយល់ពីរបៀបប្រើប្រាស់ឧបករណ៍ឲ្យបានត្រឹមត្រូវក្នុងអំឡុងពេលអូសពង្រោះគ្រប់ពេល និងការរក្សាទុកឧបករណ៍ក្នុងលក្ខខណ្ឌល្អកំឡុងពេលមិនប្រើប្រាស់។
- ❖ កំរិតនៃការដុះពន្លករបស់ពូជ: កំរិតនៃការដុះពន្លករបស់ពូជវាបានជះឥទ្ធិពលដល់ការដុះរបស់គ្រាប់ស្រូវ។
- ❖ កុំឲ្យពូជសើមខ្លាំងពេក: ពូជសើមខ្លាំងពេកលំបាកក្នុងការជ្រុះ។
- ❖ ចំនួនធ្លាក់ពូជត្រឹមត្រូវ: ការកែតម្រូវរន្ធបានត្រឹមត្រូវដើម្បីទម្លាក់គ្រាប់ពូជគឺ70-80 kg/ហត។
- ❖ អូសពង្រោះក្នុងជួរត្រង់: ប្រើខ្សែមេនាំមុខដើម្បីអូសបានត្រង់ជួរ។

**ផ្នែកអនុវត្តជាក់ស្តែង (ប្រហែល 30-60 នាទីដោយមានការរៀបចំយ៉ាងត្រឹមត្រូវទុកជាមុន):**

1) រៀបចំដី 2-3 ថ្ងៃមុនពេលអនុវត្តន៍

2) ពន្យល់ពីឧបករណ៍ត្រាំស៊ីឌ័រ/ របៀបប្រើប្រាស់ និងរបៀបថែរក្សា

3) ការកំណត់រន្ធនៅលើឧបករណ៍ដើម្បីកែតម្រូវនៃការជម្រុះចំនួនពូជ

4) ការច្រកពូជចូលទៅក្នុងប្រអប់អូសឧបករណ៍ត្រាំស៊ីឌ័រ

5) កំណត់បន្ទាត់នាំមុខលើកដំបូងនៅក្នុងស្រែដើម្បីអនុវត្តតាម

6) ការអនុវត្តអូសពង្រោះតាមបន្ទាត់ដែលបានកំណត់

7) ត្រួតពិនិត្យមើលដើម្បីបញ្ជាក់ពីចំនួនគ្រាប់ពូជដែលបានធ្លាក់ចុះ

8) ត្រួតពិនិត្យកំរិតទឹកឲ្យទាបល្មមដើម្បីរក្សាផ្ទៃដីឲ្យសើមរហូតដល់ស្រូវដុះរឹងមាំហើយអាចឈរដោយខ្លួនឯងបានមុនពេលបញ្ចូលទឹកដើម្បីគ្រប់គ្រងស្មៅ(5-7ថ្ងៃ)

**ផ្នែកឆ្លុះបញ្ចាំការបណ្តុះបណ្តាល (10 នាទី): ឆ្លុះបញ្ចាំងមេរៀនដែលបានរៀនរួច (ពីទ្រឹស្តី និងការអនុវត្ត)**

## ❖ វិធីសាស្ត្រអូសពង្រោះដោយឧបករណ៍ (ព្រោះនៅក្នុងស្រែលើដីសើម)

### ការពង្រោះនៅលើដីសើមដោយវិធីសាស្ត្រផ្សេងគ្នា



ថ្នាលសំណាប- ការស្ទូង



ការអូសពង្រោះ



ការពង្រោះដោយដៃ

| វិធីសាស្ត្រ | ថ្នាលសំណាប (ការស្ទូងគឺចាំបាច់) | ការអូសពង្រោះដោយឧបករណ៍ (ផ្ទាល់) | ពង្រោះដោយដៃ (ផ្ទាល់) |
|---|---|---|---|
| លក្ខណ:របស់វិធីសាស្ត្រនិមួយៗ | ការលូតលាស់របស់ស្រូវគឺល្អដូចការលូតលាស់របស់សំណាបក្នុងដំណាក់កាល 20ថ្ងៃដំបូងនៃការរៀបចំថ្នាលពិសេស។ ពេលដែលសំណាបត្រូវបានយកទៅស្ទូងក្នុងស្រែ ការលូតលាស់របស់វារឹតតែល្អប្រសើរ និងបែកគុម្ពបានល្អ។ | នៅក្នុងវិធីសាស្ត្រនេះថ្នាលសំណាបត្រូវបានរំលង ហើយស្រែត្រូវបានធ្វើជាថ្នាលធំមួយ។ វានៅតែអាចព្រួសជាជួរបាន ហើយរក្សាប្រសិទ្ធភាពបានដូចការស្ទូងជាជួរដែរដូចជា មានខ្យល់ចេញចូលគ្រប់គ្រាន និងងាយស្រួលក្នុងការគ្រប់គ្រងស្មៅ។ | បន្ទាប់ពីការរៀបចំដីពូជ (ដុះពន្លក)គឺ ត្រូវបានយកទៅព្រួសដោយដៃ។កំរិតដង់ស៊ីតេគ្រាប់ពូជគឺរងផលប៉ះពាល់យ៉ាងខ្លាំងដោយអ្នកព្រួស។វិធីព្រួសនេះគឺធ្វើឡើងដោយចៃដន្យ។ |
| ការលូតលាស់របស់ដំណាំស្រូវ | បរិស្ថានលូតលាស់ល្អបំផុតគឺត្រូវបានធានា។ | ការលូតលាស់ល្អត្រូវបានរំពឹងទុកប្រសិនបើការគ្រប់គ្រងស្មៅបានល្អ។ | ស្រូវអាចដុះមកស្តួចដោយសារដង់ស៊ីតេរីកលូតលាស់ខ្ពស់ដែលនាំឲ្យទទួលបានទិន្នផលទាប។ |
| ការគ្រប់គ្រងស្មៅ | ងាយស្រួលក្នុងការគ្រប់គ្រងស្មៅដោយសារមានចន្លោះរវាងគុម្ពនិមួយៗដែលបង្កើតឡើងដោយការស្ទូងជាជួរ។ | វាក៏មានលក្ខណ:ងាយស្រួលក្នុងការគ្រប់គ្រងស្មៅដូចការស្ទូងជាជួរដែរដោយសារវាមានចម្ងាយជាក់លាក់នៅចន្លោះជួរ។ ចម្ងាយអាចត្រូវបានកែតម្រូវ។ | មានភាពលំបាកក្នុងការគ្របគ្រងស្មៅដោយគ្មានទឹក និងប្រសិទ្ធភាពល្អនៃការប្រើប្រាស់ថ្នាំកំចាត់ស្មៅ(ថ្នាំគីមី)។ |
| ទិដ្ឋភាពប្រាក់ចំណាយ និងចំណេញ | មានការសន្សំសំចៃខ្ពស់ដោយការប្រើប្រាស់ទុនតិច(ពូជ, ជី) អាចធ្វើឲ្យទទួលបានទិន្នផលខ្ពស់ ប៉ុន្តែវាត្រូវការកំលាំងពលកម្ម និងប្រើប្រាស់ពេលវេលាដែលអាចធ្វើឲ្យការចំណាយថ្លៃដើមខ្ពស់។ | ប្រសិនបើឧបករណ៍ត្រាំស៊ីឌ័រត្រូវបានទិញក្នុងតម្លៃសមរម្យ វាអាចជួយកាតបន្ថយថ្លៃពលកម្មយ៉ាងមានប្រសិទ្ធភាព វាបានរួមចំណែកក្នុងការបង្កើនប្រាក់ចំណេញផងដែរ។ | ការព្រោះគឺងាយស្រួលប៉ុន្តែវាអាចប្រឈមនិងបញ្ហាស្មៅ ត្រូវការជីច្រើន និងវាអាចធ្វើឲ្យស្រូវដួលដើមដែលនាំឲ្យទទួលបានទិន្នផលទាប។ |



ប្រយ័ត្ន: វិធីសាស្ត្រសាបព្រោះនិមួយៗមានគុណសម្បត្តិ និងគុណវិបត្តិផ្សេងៗគ្នា ដូច្នេះគឺទាមទាឲ្យមានការសម្រេចចិត្តដោយផ្អែកលើគ្រប់ស្ថានភាពជាក់លាក់មួយនៃស្ថានភាពសង្គមសេដ្ឋកិច្ចជាពិសេសកំលាំងពលកម្ម។ ទោះបីការពង្រោះដោយដៃមើលទៅហាក់បីដូចជាសាមញ្ញក៏ដោយក៏ប៉ុន្តែវាទាមទារឲ្យមានការប្រុងប្រយ័ត្នក្នុងទិដ្ឋភាពមួយចំនួនដើម្បីបង្កើនទិន្នផលដូចជាកំរិតដង់ស៊ីតេគ្រាប់ និងការគ្រប់គ្រងស្មៅជាដើម។

## ❖ វិធីសាស្ត្រអូសពង្រោះដោយឧបករណ៍ (ព្រោះនៅក្នុងស្រែនៅលើដីសើម)

រាល់ពត៌មានលំអិតអំពីឧបករណ៍ត្រាំស៊ីឌ័រសូមពិនិត្យមើលនៅក្នុងសៀវភៅរបៀបប្រាស់ឧបករណ៍ព្រួសជាជួរ




វិធីសាស្ត្រក្នុងការដាក់ជីបំប៉ន
លើកទី២ (ជំហាន៤)

# ❖ វិធីសាស្ត្រដាក់ជីបំប៉ន- ជាពិសេសការដាក់ជីបំប៉នលើកទី២

## គោលបំណង

- ដើម្បីផ្តល់សារធាតុចិញ្ចឹមឲ្យត្រូវតាមពេលវេលាដើម្បីឲ្យស្រូវលូតលាស់បានល្អបំផុត និងទទួលបានទិន្នផលខ្ពស់។

## អ្វីដែលត្រូវរៀបចំ

1. ជីសម្រាប់ដាក់បំប៉នលើកទី២ (អ៊ុយរ៉េ)

## ពេលដែលត្រូវធ្វើ

- បន្ទាប់ពីការបញ្ជាក់នៃកំណរកំណើតគូរ (P.I.) ដែលជាសញ្ញាបង្ហាញសម្រាប់ការដាក់ជីបំប៉នលើកទី២

## វិធីធ្វើ

**ពន្យល់ផ្នែកទ្រឹស្តី (30-នាទី):**

1)ត្រួតពិនិត្យវត្តមានដើម្បីបង្កើនប្រសិទ្ធភាពនៃការបង្រៀន

2) ពន្យល់ពីគោលបំណង និងគុណប្រយោជន៍នៃបច្ចេកទេស

បង្កើនការយល់ដឹងអំពីការសម្រេចពេលវេលានៃការដាក់ជីឲ្យសមស្របបំផុតសម្រាប់ការរីកលូតលាស់លក្ខណៈរូបរាងរបស់ដំណាំស្រូវនៅក្នុងការអភិវឌ្ឍរូបរាងរបស់រុក្ខជាតិ(វគ្គលូតលាស់) ហើយនឹងផលិតភាពគ្រាប់(វគ្គបង្កបង្កើនផល)។ ដោយការយល់ដឹងត្រឹមត្រូវអំពីការដាក់ជីបំប៉ន វាបានបង្កើនឱកាសនៃការទទួលបានទិន្នផលខ្ពស់ខណៈពេលដែលបញ្ចៀសបានការបាត់បង់ដោយសារស្រូវដួលដើមជាដើម។

3) មូលដ្ឋានចាំបាច់ដើម្បីសម្រេចបានលទ្ធផលល្អក្នុងការលូតលាស់របស់សំណាប

❖ ពេលវេលានៃការដាក់ជីបំប៉ន:

- ការដាក់ជីទ្រាប់បាត: ក្នុងពេលរៀបចំដីស្រែ។
- ការដាក់ជីបំប៉នលើកទីមួយ: 20-30 ថ្ងៃបន្ទាប់ពីស្ទូងរួច ឬ40-50ថ្ងៃបន្ទាប់ពីការអូសពង្រោះ។
- ការដាក់ជីបំប៉នលើកទីពី: ដោយការបញ្ជាក់កំណកំណើតគូរក្នុងប្រវែង 1-2 cm។

❖ ប្រភេទ និងចំនួនជី: ជីDAP 50kg/ហត សម្រាប់ទ្រាបបាត ជីអ៊ុយរ៉េ 50kgសម្រាប់ការដាក់ជីបំប៉នលើកទី១ និងជីអ៊ុយរ៉េ 50kg សម្រាប់ការដាក់ជីបំប៉នលើកទី២។

**ផ្នែកអនុវត្តជាក់ស្តែង (ប្រហែល 30-60 នាទីដោយមានការរៀបចំយ៉ាងត្រឹមត្រូវទុកជាមុន):**

1) កាត់យកដើមស្រូវមួយចំនួនដើម្បីយកមកពិនិត្យកំណកំណើតគូរ
2) បង្ហាញដល់កសិករចូលរួមពីរបៀបចិតបកដើមស្រូវដើម្បីពិនិត្យកំណកំណើតគូរ(ទំព័រ 34)
3) ពិចារណាអំពីចំនួនជីអ៊ុយរ៉េដែលត្រូវដាក់ដោយផ្អែកលើទំហំស្រែ(50គក/ហិចតា)
4) ត្រូវប្រាកដថាស្រែមានទឹក (គ្មានទឹកគ្មានការដាក់ជីបំប៉ន)
5) អនុវត្តបាចជីឱ្យបានស្មើតាមលទ្ធភាពដែលអាចធ្វើទៅបាន

**ផ្នែកឆ្លុះបញ្ចាំការបណ្តុះបណ្តាល (10 នាទី): ឆ្លុះបញ្ចាំងមេរៀនដែលបានរៀនរួច (ពីទ្រឹស្តី និងការអនុវត្ត)**

## ❖ វិធីសាស្ត្រដាក់ជីបំប៉ន- ពេលវេលាក្នុងការដាក់ជីបំប៉ន




មើលទំព័រ 34

## ❖ វិធីសាស្ត្រដាក់ជីបំប៉ន- របៀបត្រួតពិនិត្យ "កំណរកំណើតគួរ" សម្រាប់ការដាក់ជីបំប៉នលើកទី 2




① ជ្រើសយកស្រូវដើមមេក្នុងគុម្ពមួយដើម
រួចកាត់យកត្រឹមគល់



② ចិតបកដើមស្រូវជារាងចំនិតត្រសក់



③ រួចពុះកាត់យកដើមស្រូវ
ប្រហែល10 cm ចេញពីគល់



④ យើងនិងអង្កេតឃើញកំណរកំណើតក្ងួរ
នៅចុងថ្នាំងរួចចិតបកដើមស្រូវនៅជុំវិញឲ្យអស់




⑤ យើងនិងឃើញកំណកំណើតក្ងួរ
ប្រវែងប្រហែល0.5 cm




កំណកំណើតក្ងួរគឺជាសញ្ញានៃការចាប់ផ្ដើមអភិវឌ្ឍបន្ទពូជនៃដំណាំស្រូវដែលត្រូវការសារធាតុនីត្រូហ្សែនច្រើនជាងមុននេះគឺជាសញ្ញាល្អសម្រាប់ការដាក់ជីបំប៉នលើកទី2។




ការសិក្សា និងការអង្កេត
មុនពេលប្រមូលផល
(ជំហាន៥)

# ❖ ការសិក្សា និងការអង្កេតមុនពេលប្រមូលផល

## គោលបំណង

- ដើម្បីអង្កេត និងស្វែងយល់អំពីស្ថានភាពនៃការលូតលាស់របស់ដំណាំស្រូវ និងសិក្សាអ្វីដែលល្អ និងអ្វីដែលមិនត្រូវអនុវត្តដើម្បីធ្វើឲ្យល្អប្រសើរឡើងនៅការដាំដុះដំណាំស្រូវសម្រាប់រដូវកាលដាំដុះបន្ទាប់។

## អ្វីដែលត្រូវរៀនចំ

1. បំពងPVC (ប្រវែង 1ម ចំនួន 2 ដើម និងប្រវែង 1.41 mចំនួន1 ដើម) សម្រាប់ការស្ទង់ទិន្នផលដោយ "វិធីសាស្ត្រវាស់ស្ទង់"
2. សម្ភារៈសិក្សាដូចជាប្រតិទិនដាំដុះដំណាំស្រូវ និងតារាងបណ្តុះបណ្តាលFFSរបស់គម្រោង

## ពេលដែលត្រូវធ្វើ

- ពីបីថ្ងៃមុនពេលប្រមូលផល

## វិធីធ្វើ

**ផ្នែកពន្យល់ទ្រឹស្តី (60នាទី)**

1)ត្រួតពិនិត្យវត្តមានដើម្បីបង្កើនប្រសិទ្ធភាពនៃការបង្រៀន

2) ពន្យល់ពីគោលបំណង និងគុណប្រយោជន៍នៃបច្ចេកទេស

ដំណាក់កាលនេះគឺឆ្លុះបញ្ចាំងទាំងអស់អំពីរាល់ដំណើការនៃការដាំដុះដំណាំស្រូវដោយផ្អែកលើការអង្កេតលើការលូតលាស់របស់ដំណាំស្រូវនៅក្នុងដំណាក់កាលលូតលាស់ផ្សេងគ្នាៗដែលជាលទ្ធផលនៃការអនុវត្តបច្ចេកទេសដាំដុះក៏ដូចជាជំនាញក្នុងការគ្រប់គ្រងរបស់កសិករផងដែរ។ កសិករចូលរួមនិងបានទស្សនកិច្ចស្រែបង្ហាញដែលគ្រប់គ្រងដោយកសិករបង្ហាញ និងស្រែកសិករផ្សេងទៀតដែលនៅក្បែរនោះក្នុងគោលបំណងដើម្បីសិក្សាប្រៀបធៀប។ ហើយការសិក្សានេះនិងត្រូវអនុវត្តជាចំណេះជាក់ស្តែងដើម្បីកែលម្អរបន្ថែមសម្រាប់ការដាំដុះរដូវកាលបន្ទាប់។ ក្នុងនាមជាមន្ត្រីផ្សព្វផ្សាយដែលជាគ្រូបណ្តុះបណ្តាលគួរតែអាចចង្អុលបង្ហាញនូវទិដ្ឋភាពសំខាន់ៗមួយចំនួននៃការលូតលាស់ និងទិន្នផលពីការអង្កេត រួចធ្វើការឆ្លុះបញ្ចាំងនូវអ្វីដែលបានកើតឡើងនៅគ្រប់ដំណាក់កាលនៃការដាំដុះដំណាំស្រូវនៅក្នុងរដូវ។

3) ទិដ្ឋភាពសំខាន់សម្រាប់ការរំលឹកឡើងវិញពីការដាំដុះដំណាំស្រូវនៅក្នុងរដូវ។

- ❖ ការប៉ាន់ប្រមាណទិន្នផលស្រូវ: ប៉ានប្រមាណទិន្នផលស្រូវដោយវិធីសាស្ត្រវាស់ស្ទង់ និងពិភាក្សាប្រសិនបើទិន្នផលច្រើនដូចអ្វីដែលបានរំពឹងទុកពីលទ្ធផលនៃការអនុវត្តរាល់បច្ចេកទេស។
- ❖ ស្មៅ: អង្កេតប្រសិនបើរបៀប និងការគ្រប់គ្រងស្មៅត្រូវបានធ្វើឡើងយ៉ាងមានប្រសិទ្ធភាព។
- ❖ ពូជលាយ: ត្រួតពិនិត្យប្រសិនបើប្រទះឃើញមានពូជលាយនៅដំណាក់កាលដំបូង និងគ្រប់គ្រងឲ្យបានត្រឹមត្រូវក្នុងករណីមានពូជលាយ។
- ❖ ស្រូវដួលដើម: អង្កេតកំរិតនៃការដួលដើមរបស់ស្រូវប្រសិនបើវាប៉ះពាល់ដល់ទិន្នផល និងគុណភាព។
- ❖ ជម្ងឺ: ពិភាក្សាករណីជម្ងឺផ្សេងៗដែលបានកើតឡើង ផលប៉ះពាល់ និងវិធីសាស្ត្រក្នុងការគ្រប់គ្រង។
- ❖ ផ្សេងៗ: ស្វែងរកបញ្ហាផ្សេងៗដែលប៉ះពាល់ដល់ទិន្នផល និងគុណភាពស្រូវនៅក្នុងរដូវ។

**ផ្នែកអនុវត្តជាក់ស្តែង (ប្រហែល60នាទីដោយមានការរៀបចំយ៉ាងត្រឹមត្រូវទុកជាមុន):**

1) ទៅទស្សនៈកិច្ចស្រែបង្ហាញ និងស្រែកសិករផ្សេងទៀតដែលនៅជុំវិញនោះ
2) ធ្វើអង្កេត និងពិភាក្សាពីការលូតលាស់របស់ស្រែផ្សេង ដោយរួមបញ្ចូលទាំងការចង្អុលបង្ហាញអំពីបុព្វហេតុដែលអាចកើតមានឡើងដល់ការលូតលាស់របស់ស្រូវ។
3) សំណាក់ (ដោយវិធីសាស្ត្រកាត់ស្ទង) ស្រូវសម្រាប់ការវាស់ស្ទង់ទិន្នផល
4) វាស់ស្ទង់ទិន្នផលក្នុង 1m x 1m ($m^2$) ក្នុងមួយហិចតា

➢ ចំណុចមួយចំនួននៃការអង្កេតលើស្ថានភាពដំណាំស្រូវ



## ❖ ការសិក្សា និងអង្កេតមុនពេលប្រមូលផល- ការប៉ាន់ប្រមាណទិន្នផលដោយ "វាស់ស្ទង់"

1. ជ្រើសរើសទីតាំងសំណាក




2. កាត់សំណាកនៅក្នុងទំហំផ្ទៃដី




កាត់យកតែស្រូវនៅក្នុងទំហំផ្ទៃដី 1ម៉ែត្រការ៉េ(m²)ប៉ុណ្ណោះ

3. សំណាកស្រូវ



4. រាប់គ្រាប់ក្នុងមួយកួរ



5. បែនជម្រុះគ្រាប់



6. ថ្លឹងចំនួនគ្រាប់




យកជញ្ជីង (ទំហំ 10-30 kg) សម្រាប់ថ្លឹងទម្ងន់គ្រាប់ដែលបែនរួច ក្នុងទំហំផ្ទៃដី 1m² រួចយកលទ្ធផលទៅគុណនិង 10,000 ដងដើម្បីស្ទង់បានទិន្នផលក្នុង 1ហិតា។ អត្រាសំណើម និងភាគរយនៃគ្រាប់ទុំគឺចាំបាច់ដើម្បីពិចារណា។

### តារាងគណនាផ្អែកលើការរាប់គ្រាប់ស្រូវក្នុងផ្ទៃដី 1m² (ឧទាហរណ៍)

| ចំនួនសំណាក | (1) ចំនួនគុម្ព /m² | (2) ចំនួនកួរ /គុម្ព | (3) ចំនួនកួរ/ m² {(1) X (2)} | (4) ចំនួនគ្រាប់/កួរ | (5) ភាគរយគ្រាប់ពេញ | (6) 1000 គ្រាប់ទម្ងន់ (g) សំណើម 13% | (7) ទិន្នផលប៉ាន់ស្មាន (kg/ហាត) |
|---|---|---|---|---|---|---|---|
| 1 | 20* | 8 | 160 | 113 | 80%** | 30g*** | 4,339 kg/ហាត |
| 2 | 20 | 7 | 154 | 120 | 80% | 30g | 4,435 kg/ហាត |
| 3 | 20 | 8 | 152 | 131 | 80% | 30g | 4,778 kg/ហាត |

**ទិន្នផលប៉ាន់ស្មាន: 4,339 ~4,778 kg/ហាត**

រូបមន្តគណនា: (1) x (2)=(ចំនួនកួរក្នុង 1 m²),
(ចំនួនកួរក្នុង 1 m²) X (4) x 0.8=(ចំនួនគ្រាប់ពេញក្នុង 1 m²),
(ចំនួនគ្រាប់ពេញក្នុង 1 m²)/1000 x30g=(ទិន្នផលក្នុង 1 m²)
(ទិន្នផលក្នុង 1 m²) x 10000 / 1000 = ទិន្នផល(kg)នៃស្រូវក្នុង 1ហាត

* ក្នុងករណីស្ទូងជាជួរដាក់លាក់ 20 cm x 25 cm, 20 គុម្ពសំណាកគំរូក្នុងទំហំផ្ទៃដី 1 m²

** សមាមាត្រនេះគឺប្រែប្រួលដោយកំរិតទុំរបស់ស្រូវ

*** ចំនួនលេខនេះគឺទម្ងន់ស្មាននៃពូជស្រូវអីនឌីកា (indica)

## ❖ ការសិក្សា និងអង្កេតមុនពេលប្រមូលផល - ឯកសណ្ឋានភាពក្នុងការលូតលាស់

?

តើមានអ្វីកើតឡើងនៅក្នុងការដាំដុះដំណាំស្រូវនេះ?

**ការសិក្សាដើម្បីកែលម្អសម្រាប់ពេលបន្ទាប់**

តើការលូតលាស់របស់សំណាបមានភាពស្មើរគ្នាដែរ ឬទេ?

តើការរៀបចំដីធ្វើឡើងបានត្រឹមត្រូវដែរ ឬទេ?

តើការគ្រប់គ្រងទឹកបានត្រឹមត្រូវដែរ ឬទេ?




ថ្នាលសំណាបគឺជាចំនុចចាប់ផ្តើមនៃការលូតលាស់របស់សំណាបឲ្យមានភាពស្មើរគ្នា ឬអត់ វាបានជះឥទ្ធិពលយ៉ាងខ្លាំងជាបន្តបន្ទាប់។

ការភ្ជួរ រាស់បំបែក និងកៀរដីបានល្អអាចជាមូលដ្ឋានសម្រាប់ការលូតលាស់របស់ស្រូវ។

ការធ្វើឲ្យល្អប្រសើរឡើងនៅការគ្រប់គ្រងទឹកអាចធ្វើឲ្យស្រូវលូតលាស់ល្អបំផុត និងកាត់បន្ថយការដុះលូតលាស់របស់ស្មៅ។

# ❖ ការសិក្សា និងអង្កេតមុនពេលប្រមូលផល - ការគ្រប់គ្រងស្មៅ

?

តើមានអ្វីកើតឡើងនៅក្នុងការដាំដុះដំណាំស្រូវនេះ?

តើការរៀបចំដីធ្វើឡើងបានត្រឹមត្រូវដែរឬទេ?

តើការគ្រប់គ្រងទឹកបានត្រឹមត្រូវដែរ ឬទេ?

តើមានការអនុវត្តន៍ការដកស្មៅដែរឬទេ?

តើការប្រើប្រាស់ថ្នាំគីមីត្រឹមត្រូវដែរឬទ?







## ការសិក្សាដើម្បីកែលម្អសម្រាប់ពេលបន្ទាប់

ការភ្ជួរ រាស់បំបែក និងកៀរដីបានល្អអាចការពារការដុះលូតលាស់របស់ស្មៅបាន។

ការធ្វើឲ្យល្អប្រសើរឡើងនៅការគ្រប់គ្រងទឹកអាចធ្វើឲ្យស្រូវលូតលាស់ល្អបំផុត និងកាត់បន្ថយការដុះលូតលាស់របស់ស្មៅ។

ការដកស្មៅនៅដំណាក់ការលូតលាស់ដំបូងរបស់ស្រូវគឺមានប្រសិទ្ធភាពខ្ពស់។

ការប្រើប្រាស់ថ្នាំដើម្បីគ្រប់គ្រងស្មៅគួរតែពិចារណាឲ្យបានត្រឹមត្រូវ។

## ❖ ការសិក្សា និងអង្កេតមុនពេលប្រមូលផល- ការជៀសវាងពូជលាយ

?

តើមានអ្វីកើតឡើងនៅក្នុងការដាំដុះដំណាំស្រូវនេះ?

តើការរៀបចំដីធ្វើឡើងបានត្រឹមត្រូវដែរ ឬទេ?

តើអ្នកបានប្រើប្រាស់ពូជដែលបានផលិតត្រឹមត្រូវដែរ ឬទេ?

តើមានការអនុវត្តដកស្មៅដែរ ឬទេ?







លទ្ធផលលក់បានក្នុងតម្លៃទាប

### ការសិក្សាដើម្បីកែលម្អ សម្រាប់ពេលបន្ទាប់

ការភ្ជួរលប់ស្រូវ(ពូជ)ដែលបានដាំដុះក្នុងរដូវកាលមុនទៅក្នុងដីបានត្រឹមត្រូវ វាអាចការពារកុំឲ្យពូកវាដុះចេញមកក្នុងរដូវដាំដុះបន្ទាប់។

ស្វែងរកប្រភពពូជពិតដែលមានគុណភាព និងភាពសុទ្ធខ្ពស់ គឺចាប់ផ្តើមធានាបាននូវការដាំដុះស្រូវល្អ។

ប្រសិនបើប្រទះឃើញមានពូជលាយនៅដំណាកកាលលូតលាស់ដំបូងរបស់ដំណាំស្រូវសូមដកវាចេញពីស្រែ។

## ❖ ការសិក្សា និងអង្កេតមុនពេលប្រមូលផល -ការបញ្ចៀសនូវស្ថានភាពស្រូវដួលដើម

?

តើមានអ្វីកើតឡើងនៅក្នុងការដាំដុះដំណាំស្រូវនេះ?

**ការសិក្សាដើម្បីកែលម្អសម្រាប់ពេលបន្ទាប់**

តើការដាក់ជីបំប៉នអនុវត្តបានត្រឹមត្រូវដែរឬទេ?

តើការលើកចងបញ្ជូរអនុវត្តន៍បានត្រឹមត្រូវដែរឬទេ?

តើការគ្រប់គ្រងទឹកបានត្រឹមត្រូវដែរ ឬទេ?






ការអនុវត្តបានត្រឹមត្រូវ និងដាក់ជីបំប៉នទាន់ពេលវេលា ដើម្បីការពារស្រូវដួលដើម



អនុវត្តន៍ដោយការចងបញ្ជូរ សម្រាប់ការសង្គ្រោះបន្ទាន់

អនុវត្តន៍បានត្រឹមត្រូវនូវការដាក់ជីបំប៉នដោយរួមបញ្ចូលទាំង1) ការដាក់ជីទ្រាប់បាត, 2) ការដាក់ជីបំប៉នលើកទី1 និង 3) ការដាក់ជីបំប៉នលើក2 គឺជាគន្លឹះមួយដើម្បីបញ្ចៀសបានស្រូវដួលដើមធ្ងន់ធ្ងរ។

ប្រសិនបើស្រូវចាប់ផ្តើមដួលដើមនៅដំណាក់កាលដំបូងនៃគ្រាប់ទុំ សូមចងគុម្ពស្រូវពីឬបីគុម្ពបញ្ចូលគ្នាបញ្ឈរដើម្បីកាត់បន្ថយការបាត់បង់បន្ថែមទៀត។

កែលម្អរការគ្រប់គ្រងទឹកឲ្យបានល្អប្រសើរអាចកាត់បន្ថយបាននូវស្រូវដួលដើម ទោះបីជាវាមានការលំបាកខ្លាំងក្នុងការអនុវត្តនៅក្នុងស្ថានភាពពិតក៏ដោយ។

# ❖ ការសិក្សា និងអង្កេតមុនពេលប្រមូលផល - ការបញ្ចៀសនូវការកើតឡើងនៃជម្ងឺ

?

តើមានអ្វីកើតឡើងនៅក្នុងការដាំដុះដំណាំស្រូវនេះ?

## ការសិក្សាដើម្បីកែលម្អ សម្រាប់ពេលបន្ទាប់

តើការធ្វើការជ្រើសពូជបានត្រឹមត្រូវដែរឬទេ?




ការជ្រើសរើសពូជរួមបញ្ចូលទាំងការលាងសំលាប់មេរោគដោយទឹកក្តៅ 60 ℃ ត្រឹមរយៈពេល10នាទីគឺមានប្រសិទ្ធភាពចំពោះការគ្រប់គ្រងជម្ងឺបានមួយចំនួន។ ការអនុវត្តន៍ការជ្រើសរើសពូជបានត្រឹមត្រូវ និងរក្សាពូជនៅក្នុងស្ថានភាពសមស្រប។

តើមានការអង្កេតជិតដល់ដែរ ឬទេ ដើម្បីពិនិត្យរកការកើតឡើងនៃជម្ងឺក្នុងដំណាក់កាលដំបូងរបស់វា?




បង្ការការព្យាបាល




ព្យាបាលរោគសញ្ញា

ករណីជម្ងឺអាចកើតមានឡើងដោយកត្តាចង្រៃមួយចំនួន។ នៅក្នុងករណីណាមួយនោះសំខាន់បំផុតគឺបង្កើតការប្រុងប្រយ័ត្ន និងចុះអង្កេតឲ្យបានទៀងទាតដើម្បីកត់ចំណាំនូវការចាប់ផ្តើមនៃជម្ងឺដើម្បីអាចឆ្លើយតបទៅនឹងជម្ងឺបាននៅដំណាក់កាលដំបូងដើម្បីកាត់បន្ថយបាននូវការបំផ្លាញ។

តើការប្រើប្រាស់ថ្នាំគីមីបានត្រឹមត្រូវដែរ ឬទេ?

ការប្រើប្រាស់ថ្នាំគីមីដើម្បីគ្រប់គ្រងជម្ងឺគួរតែពិចារណាឲ្យបានត្រឹមត្រូវនៅការប្រើប្រាស់ និងពេលវេលា។

## ❖ ការសិក្សា និងអង្កេតមុនពេលប្រមូលផល- ត្រូវការការអនុវត្តន៍ល្អនៅគ្រប់ដំណាក់កាលនិមួយៗ

?

តើមានអ្វីកើតឡើងនៅក្នុងការដាំដុះដំណាំស្រូវនេះ?

**ការសិក្សាដើម្បីកែលម្អ សម្រាប់ពេលបន្ទាប់**

តើគ្រប់ដំណាក់កាលនៃដាំដុះដំណាំស្រូវអនុវត្តន៍បានត្រឹមត្រូវទាំងមូលដែរឬទេដើម្បីឈានទៅទទួលបានលទ្ធផលល្អប្រសើរ?




គ្រប់ដំណាក់កាលនៃបច្ចេកទេសដាំដុះដំណាំស្រូវគឺមានទំនាក់ទំនងគ្នាទៅវិញទៅមកទៅតាមលំដាប់លំដោយ ដូច្នេះការសម្រេចបានលទ្ធផលល្អប្រសើរនៅក្នុងដំណាក់កាលនិមួយៗនិងឈានទៅសម្រេចបានលទ្ធផលល្អប្រសើរនៅក្នុងលក្ខខណ្ឌទិន្នផល និងគុណភាពដើម្បីទទួលបានប្រាក់ចំណេញខ្ពស់ពីការធ្វើកសិកម្មទាំងមូល។

# តួនាទីរំពឹងទុកនៃមន្ត្រីផ្សព្វផ្សាយ កសិករបង្ហាញ និងកសិករចូលរួម

| | | |
|---|---|---|
| Ex | មន្ត្រីផ្សព្វផ្សាយ | មន្ត្រីផ្សព្វផ្សាយ (EX) បង្កើតការរៀបចំទីតាំងបណ្តុះបណ្តាលទាំងទ្រឹស្តី និងការអនុវត្តន៍រួមគ្នាជាមួយកសិករបង្ហាញ។ ការបរិច្ឆេទនៃវគ្គបណ្តុះបណ្តាលសាលារៀនស្រែកសិករ(FFS) និងត្រូវប្រកាសដល់កសិករចូលរួមដែលមានសក្តានុពលនៅក្នុងតំបន់ជុំវិញទីតាំងបណ្តុះបណ្តាល។ មន្ត្រីផ្សព្វផ្សាយដើរតួនាទីជាគ្រូបណ្តុះបណ្តាល និងជាអ្នកសម្របសម្រួល។ |
| DF | កសិករបង្ហាញ | កសិករបង្ហាញ(DF) ផ្តល់ទីតាំងបណ្តុះបណ្តាលដល់កសិករចូលរួម។ កសិករបង្ហាញត្រូវអនុវត្តរាល់បច្ចេកទេសនៃការដាំដុះដំណាំស្រូវដែលណែនាំដោយគម្រោង APPP តាមរយៈការបណ្តុះបណ្តាលរបស់មន្ត្រីផ្សព្វផ្សាយ។ |
| PF | កសិករចូលរួម | កសិករចូលរួម (PF) គឺជាអ្នកទទួលបានចំណេះដឹងអនុវត្តជាក់ស្តែងតាមរយៈសាលារៀនស្រែកសិករ ហើយរំពឹងថាពួកគាត់និងយកចំណេះដឹងដែលបានរៀនទៅអនុវត្តនៅក្នុងការដាំដុះដំណាំស្រូវ ជាក់ស្តែងរបស់ពួកគាត់។ កសិករចូលរួមអាចក្លាយជាកំលាំងនៃកសិករទៅ កសិករ (Farmer to Farmer) ដោយផ្អែកលើប្រព័ន្ធផ្សព្វផ្សាយ។ |



# ការកំណត់កាលបរិច្ឆេទវគ្គបណ្ដុះបណ្ដាលសាលារៀនស្រែកសិករ(FFS)



ក្នុងគោលបំណងដើម្បីសិក្សាចំណុចទិដ្ឋភាពក្បេ្យត្រសាស្រ្តបន្ថែមផ្សេងទៀតសូមមើលនៅក្នុងសៀវភៅបច្ចេកទេសខាងក្រោម ដែលបង្កើតឡើងសម្រាប់កសិករទូទៅ ដោយរួមបញ្ចូលទាំងមាតិកាមួយចំនួនសម្រាប់មន្រ្តីផ្សព្វផ្សាយផងដែរ។



# តារាងវគ្គបណ្តុះបណ្តាលសាលារៀនស្រែកសិករ(FFS )របស់គម្រោងAPPP




មន្ត្រីផ្សព្វផ្សាយ (រូបឈរខាងស្តាំ) កំពុងបង្រៀនដោយប្រើប្រាស់តារាង (ព្រីនលើPVC )សម្រាប់ធ្វើការពន្យល់ ដល់កសិករដែលបានចូលរួមក្នុងវគ្គបណ្តុះបណ្តាល FFSដែលបានធ្វើឡើងនៅទីតាំងរបស់កសិករបង្ហាញ




## គម្រូបទីពីរ

បង្ហាញពីលំហូរទាំងមូលនៃវដ្តក្នុងការដាំដុះដំណាំស្រូវនិងទំនាក់ទំនងរវាងកសិករ និងដំណាំស្រូវៗកត់ចំណាំនូវសារៈសំខាន់ក្នុងការគ្រប់គ្រងឲ្យបានត្រឹមត្រូវ នៃដំណាក់កាលដាំដុះនិមួយៗ។




## FFS1-ប្រធានបទទី១

ពន្យលពីទំនាក់ទំនងរវាងប្រាក់ចំណូល ចំណាយ និងប្រាក់ចំណេញ។ ការប្រៀបកំរិតនៃការយល់ដឹងរបស់កសិករពីរបៀបគ្រប់គ្រងហិរញ្ញវត្ថុរបស់ពួកគាត់។




**FFS1-ប្រធានបទទី២**

ពន្យល់ពីឥទ្ធិពលនៃរបបទឹកភ្លៀងទៅលើជម្រើសនៃប្រព័ន្ធដាំដុះដំណាំស្រូវ។ ការសិក្សាពីលក្ខខណ្ឌអំណោយផលក្នុងតំបន់របស់កសិករ។

FFS1-3

# គុណប្រយោជន៍នៃការគ្រប់គ្រងទឹក




ចូរព្យាយាមកែលំអប្រព័ន្ធផ្គត់ផ្គង់ទឹករបស់អ្នកក្នុងកំឡុងរដូវប្រាំង!! ព្រោះវាជាពេលដែលមានលក្ខណៈងាយស្រួលក្នុងការគ្រប់គ្រង ដោយសារគ្មានភ្លៀងធ្លាក់។

**FFS1-ប្រធានបទទី៣**

បង្ហាញពីតួនាទីនៃប្រព័ន្ធផ្គត់ផ្គង់ទឹកក្នុងរដូវប្រាំង និងវស្សា។ ស្នើដល់កសិករឲ្យចេះកែលម្អប្រព័ន្ធផ្គត់ផ្គង់ទឹករបស់ពួកគាត់តាមគ្រប់មធ្យោបាយ។

FFS1-4

# បច្ចេកទេសលាងសំអាតគ្រាប់ពូជស្រូវ

## របៀបទី1. ការលាងសំអាតពូជ



ជំហានទី1.

ច្រកពូជស្រូវក្នុងថង់ស្បៃអ៊ីយ



ជំហានទី2.

ធ្វើល្បាយទឹកជីអ៊ុយរ៉េ ដោយប្រើទឹកទម្ងន់40 គ.ក្រ និងជីអ៊ុយរ៉េ 20គ.ក្រ

ការត្រួតពិនិត្យទឹកជីដោយប្រើស៊ុតស្រស់អណ្តែត



ជំហានទី3.

កូរស្រូវពូជឲ្យសព្វជាមួយទឹកជីអ៊ុយរ៉េ

ដួសយកគ្រាប់ស្រូវអណ្តែតចេញ



ជំហានទី4.

លាងសំអាតក្នុងទឹកស្អាត

## របៀបទី2. ការសំលាប់មេរោគដោយទឹកក្តៅ



ជំហានទី1.

រៀបចំចង្ក្រានដាំទឹក

ដាំទឹកឲ្យក្តៅកម្រិត 60អង្សាសេ



ជំហានទី2.

ដាក់ថង់ពូជស្រូវក្នុងទឹកក្តៅ រួចត្រលែងឲ្យសព្វរយៈពេល10នាទី

ពិនិត្យពេល 10នាទីជាក់លាក់ បន្ទាប់មកលើកថង់ពូជស្រូវចេញ



ជំហានទី3.

លាងសំអាតពូជស្រូវក្នុងទឹកត្រជាក់ស្អាត



ជំហានទី4.

ហាលឲ្យស្ងួតរួចរក្សាទុកនៅកន្លែងស្អាត និងស្ងួត ក្នុងករណីមិនទាន់ត្រូវការសាបភ្លាមៗ។

## ការគ្រប់គ្រងពេលវេលាសម្រាប់សាប

ត្រាំពូជស្រូវក្នុងទឹកត្រជាក់រយៈពេល24ម៉ោង និងផ្អាប់រយៈពេល24 ម៉ោង ដើម្បីឲ្យមានដំណុះល្អ

ឬ ,

ក្នុងករណីមិនទាន់អាចសាបបាន ត្រូវហាលពូជស្រូវឲ្យស្ងួតមានសំណើម 12 -13% រក្សាទុកបានរយៈពេល3ខែ

**FFS1-ប្រធានបទទី៤**

ពន្យល់ពីគោលបំណងនៃការជ្រើសរើសពូជ និងហេតុអ្វីបានវាចាំបាច់។ សិក្សាពីជំហាននិមួយៗយ៉ាងយកចិត្តទុកដាក់ ដើម្បីអាចយកទៅអនុវត្តបានយ៉ាងត្រឹមត្រូវ។

FFS2- ប្រធានបទទី១

ពន្យល់បន្ថែមពីការលាងសំអាតពូជ និងការរៀបចំថ្នាលសំណាបក្នុងពេលវេលាដ៏សមស្រប។

FFS2-1

## ការលាងសំអាតពូជ

ត្រាំពូជស្រូវក្នុងទឹកត្រជាក់រយៈពេល24ម៉ោង និងផ្អាប់រយៈពេល 24 ម៉ោងដើម្បីឲ្យមានដំណុះល្អ

ថ្ងៃទី1

ថ្ងៃទី 2



ការជ្រើសរើសពូជ និងការសំលាប់មេរោគដោយទឹកក្តៅ

ត្រាំ១ថ្ងៃក្នុងទឹក

ផ្អាប់ទុក១ថ្ងៃ

ថ្ងៃទី ៣

## ការរៀបចំថ្នាលសំណាបទុកជាមុន (មុនពេលលាងសំអាតពូជ២-៣ថ្ងៃ)

រៀបចំថ្នាលសំណាប និងសាប



FFS2-2

# ការរៀបចំថ្នាលសំណាប(៣ ឬ ៤សប្តាហ៍មុនពេលស្ទូង)

**1. ការលើករង**




**2. ការបន្ថែមជីសរីរាង្គ**




**3. ការបន្ថែមធ្យូងអង្កាម**




**4. ការលាយច្របល់ធ្យូងអង្កាមជាមួយដី**




**5. ការកៀរពង្រាបដី**




**6. ការដាក់ជីទ្រាប់បាត(DAP: ៩ក្រ/ម២)**




**7. ការសាបគ្រាប់ពូជដែលដុះពន្លក (៥០ក្រ/ម2)**




**ទំហំថ្នាលសំណាប:**

- ថ្នាលសំណាបទំហំ៤០០ទៅ៥០០ម2 អាចស្ទូងបានលើផ្ទៃដី១ហ.ត
- គ្រាប់ពូជសុទ្ធដែលមានគុណភាព៤០ទៅ៥០ គ.ក អាចសាបសំរាប់ស្ទូងលើផ្ទៃដី១ហ.ត។



សូមរក្សាទឹកក្នុងថ្នាលសំណាបឲ្យបានកំរិតពី៣ ទៅ ៥ ស.ម កុំឲ្យស្ងួត។ ចូរសង្កេតឲ្យបានដិតដល់ដើម្បីស្វែងរករោគសញ្ញានៃជម្ងឺ!

**FFS2- ប្រធានបទទី២**

បង្ហាញពីជំហានមូលដ្ឋានក្នុងការរៀបចំថ្នាលសំណាប។ បង្ហាញឲ្យច្បាស់ថា ការរៀបចំថ្នាលសំណាបគួរតែត្រូវបានរៀបចំនៅកន្លែងដែលមានប្រព័ន្ធផ្គត់ផ្គង់ទឹកគ្រប់គ្រាន់។

# ការរៀបចំដី និង ការកៀរពង្រាប(១ សប្តាហ៍មុនពេលស្ទូង)

FFS3-1

①ការភ្ជួរស្រែ ②ការរស់បំបែកដី ③ការកៀរពង្រាប ④ ការកៀពង្រាបសំរេច



## ការកៀរពង្រាបដីបានល្អ




## ការកៀរពង្រាបដីពុំបានល្អ





ផ្ទៃដីស្រែដែលរាបស្មើហើយមានទឹកគ្រប់គ្រាន់គឺងាយស្រួលក្នុងការគ្រប់គ្រងស្មៅ និងធ្វើឲ្យស្រូវលូតលាស់ស្មើគ្នា!!

### FFS3- ប្រធានបទទី១

ពន្យល់ពីសារៈសំខាន់នៃការរៀបចំដី ពីព្រោះវាបានផ្តល់នូវមូលដ្ឋានលក្ខខណ្ឌជោគជ័យក្នុងការដាំដុះដំណាំស្រូវ ដូចជាងាយស្រួលក្នុងការគ្រប់គ្រងទឹក និងស្មៅជាដើម។

FFS3-2

# វិធីស្ទូងជាជួរ




## វិធីស្ទូងដែលត្រឹមត្រូវ

- ប្រើសំណាបដែលបានសាបត្រឹមត្រូវ(សំណាបដែលមានអាយុចាប់ពី១៨-២១ថ្ងៃ)
- ស្ទូងដោយប្រើខ្សែបន្ទាត់ ឬ ជួរមេ
- ទុកចន្លោះ២០ស.ម ទៅ ២៥ស.ម ពីគុម្ពមួយទៅគុម្ពមួយ
- ស្ទូងដោយសំណាប២ទៅ៣ដើមក្នុងមួយគុម្ព។



## សារៈប្រយោជន៍នៃការស្ទូងជាជួរ

- សន្ទូងលូតលាស់ល្អ ព្រោះមានចន្លោះពីគុម្ពមួយទៅគុម្ពត្រឹមត្រូវ
- មានខ្យល់ចេញចូលគ្រប់គ្រាន់ ហើយធ្វើឲ្យស្រូវបែកគុម្ពល្អ និង ជួយកំចាត់បាននូវភ្នាក់ងារបង្កជម្ងឺដែលបណ្តាលមកពីការប្រើប្រាស់ជីគីមី
- ងាយស្រួលក្នុងការថែទាំ និងដកស្មៅ

### FFS3-ប្រធានបទទី២

ពន្យល់ពីសារៈសំខាន់នៃការទុកចន្លោះសមស្រមពីគុម្ពស្រូវមួយទៅគុម្ពស្រូវមួយទៀត ដោយវិធីសាស្រ្តស្ទូងជាជួរ ដែលជាកក្តាធ្វើឲ្យស្រូវលូតលាស់ល្អ និងផ្តល់ទិន្នផលខ្ពស់។

# សារៈសំខាន់នៃការដកស្មៅ

FFS3-3

**FFS3-ប្រធានបទទី៣**

ពន្យល់ពីសារៈសំខាន់នៃការគ្រប់គ្រងស្មៅ។
វិធីសាស្រ្តដែលអាចណែនាំដល់កសិករួមមាន៖ ការដកស្មៅដោយដៃ ការគ្រប់គ្រងទឹកបានត្រឹមត្រូវ ឬ ក្នុងករណីចាំបាច់អាចណែនាំឲ្យប្រើថ្នាំគីមី។

កសិករដែលដកស្មៅ
ជាប្រចាំ








ចំណេញ
ច្រើន!!



កសិករដែលមិនបាន
ថែទាំនិងដកស្មៅ
បានត្រឹមត្រូវ





ស្មៅគឺជាប្រភពនៃមេរោគ ពពួកបាក់តេរី និងសត្វល្អិតចង្រៃ
ផ្សេងៗ ដែលជាភ្នាក់បង្កជម្ងឺដល់ដំណាំស្រូវ។

ចំណេញ
តិច...



FFS4-1

# ការដាក់ជីបំប៉ន



| | | |
|---|---|---|
| | ការដាក់ជីទ្រាប់បាត ពេលរៀបចំដី | ជី ដេ អា ប៉េ ៥០ គ.ក្រ/ហ.ត |
| | ដាក់ជីបំប៉នលើកទី១ ក្រោយពេលស្ទូង២០ ទៅ ២៥ថ្ងៃ | ជីអ៊ុយរ៉េ ៥០ គ.ក្រ/ហ.ត |
| | ដាក់ជីបំប៉នលើកទី២ ពេលចេញកំណរ កំណើតកួរ | ជីអ៊ុយរ៉េ ៥០ គ.ក្រ/ហ.ត |









សូមប្រាកដថាស្រែរបស់អ្នកមានទឹកគ្រប់គ្រាន់!!!

ត្រួតពិនិត្យកំណរកំណើតកួរ ដើម្បីកំណត់ពេលសមស្រម បំផុតក្នុងការដាក់ជីបំប៉ន!



ចូរគិតពិចារណាអំពីពេលវេលាដែលសមស្របក្នុងការប្រើប្រាស់ជី ដើម្បីធ្វើឲ្យស្រូវលូតលាស់ល្អ នឹងទទួលបានទិន្នផលខ្ពស់ៗ

**FFS4-ប្រធានបទទី១**

ពន្យល់ពីសារៈសំខាន់នៃការដាក់ជីទាំងបីលើកដើម្បីឲ្យស្រូវលូតលាស់ល្អនិងទទួលបានទិន្នផលខ្ពស់ ហើយអាចកាត់បន្ថយហានិភ័យដូចជាស្រូវដួលដើមជាដើម។




**FFS4-ប្រធានបទទី២**

ពន្យល់ពីភាពខ្វះខ្វាយកើនឡើងពីការបាត់បង់ដោយស្ថានភាពស្រូវដួលដើម។ បង្កើនចំណេះដឹង និងពិភាក្សារកដំណោះស្រាយទាក់ទងនិងបញ្ហានេះ។

## ❖ ការសិក្សា និងអង្កេតមុនពេលប្រមូលផល- ការប៉ាន់ប្រមាណទិន្នផលដោយ "វាស់ស្ទង់"

FFS5-1

1. ជ្រើសរើសទីតាំងសំណាក




2. កាត់សំណាកនៅក្នុងទំហំផ្ទៃដី




3. សំណាកស្រូវ



4. រាប់គ្រាប់ក្នុងមួយកួរ



5. បែនជម្រុះគ្រាប់



6. ថ្លឹងចំនួនគ្រាប់




កាត់យកតែស្រូវនៅក្នុងទំហំផ្ទៃដី 1ម៉ែត្រការ៉េ(m²)ប៉ុណ្ណោះ

យកជញ្ជីង (ទំហំ 10-30kg) សម្រាប់ថ្លឹងទម្ងន់គ្រាប់ដែលបែនរួចក្នុងទំហំផ្ទៃដី 1m² រួចយកលទ្ធទៅគុណនិង 10,000 ដងដើម្បីស្ទង់បានទិន្នផលក្នុង 1ហិតា។ អត្រាសំណើម និងភាគរយនៃគ្រាប់ទុំគឺចាំបាច់ដើម្បីពិចារណា។

**តារាងគណនាផ្អែកលើការរាប់គ្រាប់ស្រូវក្នុងផ្ទៃដី 1m² (ឧទាហរណ៍)**

| ចំនួនសំណាក | (1) ចំនួនគុម្ព /m² | (2) ចំនួនកួរ /គុម្ព | (3) ចំនួនកួរ/ m² {(1) X (2)} | (4) ចំនួនគ្រាប់/កួរ | (5) ភាគរយគ្រាប់ពេញ | (6) 1000 គ្រាប់ទម្ងន់ (g) សំណើម 13% | (7) ទិន្នផលប៉ាន់ស្មាន (kg/ហត) |
|---|---|---|---|---|---|---|---|
| 1 | 20* | 8 | 160 | 113 | 80%** | 30g*** | 4,339 kg/ហត |
| 2 | 20 | 7 | 154 | 120 | 80% | 30g | 4,435 kg/ហត |
| 3 | 20 | 8 | 152 | 131 | 80% | 30g | 4,778 kg/ហត |

**ទិន្នផលប៉ាន់ស្មាន: 4,339 ~4,778 kg/ហត**

រូបមន្តគណនា: (1) x (2)=(ចំនួនកួរក្នុង 1 m²),
(ចំនួនកួរក្នុង 1 m²) X (4) x 0.8=(ចំនួនគ្រាប់ពេញក្នុង 1 m²),
(ចំនួនគ្រាប់ពេញក្នុង 1 m²)/1000 x30g=(ទិន្នផលក្នុង 1 m²)
(ទិន្នផលក្នុង 1 m²) x 10000 / 1000 = ទិន្នផល(kg)នៃស្រូវក្នុង 1ហាត

* ក្នុងករណីស្ទូងជាជួរជាក់លាក់ 20 cm x 25 cm, 20 គុម្ពសំណាកគំរូក្នុងទំហំផ្ទៃដី 1 m²

** សមាមាត្រនេះគឺប្រែប្រួលដោយកំរិតទុំរបស់ស្រូវ

*** ចំនួនលេខនេះគឺទម្ងន់ស្មាននៃពូជស្រូវអីនឌីកា (indica)

FFS5-ប្រធានបទទី១

ការរៀបចំតារាងនេះទុកមុនថ្ងៃធ្វើទិវា។ ដូច្នេះ ក្នុងថ្ងៃធ្វើទិវា អ្នកចូលរួមអាចរៀនពីការស្ទង់ទិន្នផលដែលជាលទ្ធផលនៃបច្ចេកទេសសាលារៀនស្រែកសិករ។

FFS5-2

FFS5-ប្រធានបទទី២

ពិភាក្សារកវិធីបញ្ចៀសនូវបុព្វហេតុដែលធ្វើឲ្យមានលាយលំជាមួយពូជស្រូវផ្សេង ឫ ឬពូជស្រូវអន់គុណភាពដែលជាហេតុធ្វើឲ្យធ្លាក់តម្លៃ។

# គុណប្រយោជន៍នៃការផ្លាស់ប្តូរពូជ

កសិករដែលដោះដូរពូជជាទៀងទាត់ ហើយប្រើប្រាស់ពូជសុទ្ធដែលមានគុណភាព





- ➢ពូជសុទ្ធល្អ (មិនលាយជាមួយពូជស្រូវផ្សេង)
- ➢ ធន់និងជម្ងឺ
- ➢អត្រាដំណុះខ្ពស់

ចំណេញច្រើន!!



កសិករដែលបន្តប្រើប្រាស់ពូជផ្ទាល់ខ្លួនពីមួយឆ្នាំទៅមួយឆ្នាំ





- ➢គ្មានភាពសុទ្ធល្អ(លាយជាមួយពូជស្រូវផ្សេង)
- ➢មិនធន់និងជម្ងឺ
- ➢អត្រាដំណុះទាប

ចំណេញតិច...





ការផ្លាស់ប្តូរពូជស្រូវថ្មីយ៉ាងហោចណាស់ធ្វើឡើង ២ ទៅ ៣ឆ្នាំម្តងដើម្បីបញ្ចៀសបាននូវការធ្លាក់ចុះគុណភាព និង ទិន្នផល ដែលជាហេតុធ្វើឲ្យប្រាក់ចំណេញធ្លាក់ចុះ!

FFS5-3

# អាសយដ្ឋានទំនាក់ទំនងក្រុមផលិតពូជគាំទ្រដោយគំរោង APPP/JICA

| ខេត្ត | ក្រុមផលិតពូជ | | ទំនាក់ទំនង |
|---|---|---|---|
| បាត់ដំបង |  | ក្រុមផលិតពូជសាមគ្គី ស្រុកបាណន់ | លោក ទង ស៊ីមន: 088-488-8523<br>លោក អ៊ិន សួន: 053-662-9696 |
| |  | ក្រុមផលិតពូជសាមគ្គី ស្រុកមោងឫស្សី | លោក មូល ម៉ឺន: 089-359-995<br>លោក ហ៊ូ ប៉ែន: 053-631-1889<br>លោកស្រី ជើង វី: 092-875-673 |
| |  | ក្រុមផលិតពូជសាមគ្គី ស្រុកបវេល | លោក ហ៊ុល ខ្លឹម: 012-675-589<br>លោក សើន ប៊ុនធឿន: 012-402-381<br>លោក ស្រី កូវ: 092-954216 |
| ពោធិ៍សាត់ |  | ស្ថានីយកសិកម្មទួលល្ពៅ | លោក ឡេង ចិន្តាមុន្នី:012-879-877<br>លោក ហៅ ចាន់ដារ៉ា: 012-635-409 |
| កំពង់ឆ្នាំង |  | ក្រុមផលិតពូជភ្នំតូចសាមគ្គី | លោក មាស សឿន: 012-681-523<br>លោក ខឹម បូរ: 092-358-997<br>លោកស្រី កែ ខាន់: 017-435-165 |



ក្រុមផលិតពូជទាំងអស់ខាងលើ គឺអនុវត្តតាមការណែនាំបច្ចេកទេសផលិតពីគំរោងបង្កើនផលិតភាពកសិកម្មក្នុងតំបន់ទន្លេសាបប៉ែកខាងលិចនៃទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន(JICA) និងប្រើប្រាស់ពូជដែលមានប្រភពពីCARDI*។
សូមធ្វើការទំនាក់នង ដើម្បីទទួលបានពូជសុទ្ធដែលគុណភាព!! *CARDI: វិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជា

## FFS5-ប្រធានបទទី៣

ណែនាំក្រុមSGGដែលគាំទ្រដោយគម្រោងAPPP ដល់ក្រុមកសិករ
ចូលរួមក្នុងស្រែបង្ហាញ ដើម្បីជំរុញពួកគេឲ្យធ្វើការផ្លាស់ប្តូរពូជរបស់ពួកគេនៅឆ្នាំក្រោយ ដោយពន្យល់ពីរបៀបដែលSSG ផលិតពូជស្រូវមានគុណភាពខ្ពស់។

# គម្រោងបង្កើនផលិតភាពកសិកម្មក្នុងតំបន់ទន្លេសាបប៉ែកខាងលិច(APPP/JICA)
## ខែតុលា ឆ្នាំ២០១០ ដល់ ខែមិនា ឆ្នាំ២០១៥




**-អក្សរកាត់-**

PDA: មន្ទីរកសិកម្មខេត្ត

DAO: ការិយាល័យកសិកម្មស្រុក

BTB: ខេត្តបាត់ដំបង

PS: ខេត្តពោធិ៍សាត់

KC: ខេត្តកំពង់ឆ្នាំង